បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 6 ខែ 06 ឆ្នាំ 2003

# មាតិកា

## I. ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៦-៧-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៣៤ ស្តីពីការបង្កើតនិងការប្រព្រឹត្តិទៅនៃសហគមន៍អភិវឌ្ឍន៍កសិកម្មសហភាពសហគមន៍អភិវឌ្ឍន៍កសិកម្មនិងបុរេសហគមន៍អភិវឌ្ឍន៍កសិកម្ម | ១៨២៥ |
| ១៦-៧-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៣៥ បញ្ឈប់ភារកិច្ចរបស់ឯកឧត្តម **សូ ម៉ារ៉ា** ពីអគ្គនាយកនៃក្រសួងទេសចរណ៍ | ១៨៤៧ |
| ១៨-៧-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៣៦ តែងតាំងឯកឧត្តម **ឆយ យីហ៊ាង** ជាប្រធាន វិទ្យាស្ថាន វប្បធម៌ និង វិចិត្រសិល្បៈ<br>-ឯកឧត្តម **ជា ឆេវាង** ជាអគ្គលេខាធិការរង នៃរាជបណ្ឌិតសភាកម្ពុជា | ១៨៤៨ |
| ១៨-៧-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៣៧ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធ ចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពល ខេមរភូមិន្ទ | ១៨៤៩ |
| ១៨-៧-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៣៨ តែងតាំងឯកឧត្តម **សួស សាម៉េត** ប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ជាឯកអគ្គរាជទូត ប្រធានស្ថាន បេសកកម្មអចិន្ត្រៃយ៍ ប្រចាំការិយាល័យអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានានៅទីក្រុងហ្សឺណែវ | ១៨៥២ |
| ២១-៧-២០០១ | -ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៣៩ តែងតាំងឯកឧត្តម **យ៉ាវ ម៉ុនម៉េង** ជាសមា ជិក ទី ១ នៃអាជ្ញាធរអគ្គិសនីកម្ពុជា | ១៨៥៣ |


## II. រាជរដ្ឋាភិបាល

### អនុក្រឹត្យ


| | | |
|---|---|---|
| ១៧-៧-២០០១ | -អនុក្រឹត្យលេខ ៦៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា | ១៨៥៤ |
| ១៧-៧-២០០១ | -អនុក្រឹត្យលេខ ៦៧ អនក្រ.បក ស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ | ១៨៥៦ |
| ០៦-៧-២០០១ | -អនុក្រឹត្យលេខ ២៩៦ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា | ១៨៥៨ |
| ០៩-៧-២០០១ | -អនុក្រឹត្យលេខ ២៩៧ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយ នគរបាលជាតិ | ១៨៥៩ |
| ០៩-៧-២០០១ | -អនុក្រឹត្យលេខ ២៩៨ អនក្រ.តត ស្តីពីការដកហូតនិងតែងតាំងឋានន្តរសក្តិនាយនគរបាលជាតិ | ១៨៦០ |
| ០៩-៧-២០០១ | -អនុក្រឹត្យលេខ ២៩៩ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយ នគរបាលជាតិ | ១៨៦១ |

០៩-៧-២០០១ -អនុក្រឹត្យលេខ ៣០០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៨៦២

០៩-៧-២០០១ -អនុក្រឹត្យលេខ ៣០១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៨៦៣

១១-៧-២០០១ -អនុក្រឹត្យលេខ ៣០២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៨៦៤

១២-៧-២០០១ -អនុក្រឹត្យលេខ ៣០៣ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៨៦៥

១២-៧-២០០១ -អនុក្រឹត្យលេខ ៣០៤ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៨៦៦

១៤-៧-២០០១ -អនុក្រឹត្យលេខ ៣០៥ អនក្រ.តត ស្តីពីការដកហូតឋានន្តរសក្តិ និងបណ្តេញចេញ ពីក្របខ័ណ្ឌនគរបាលជាតិ ១៨៦៧

១៦-៧-២០០១ -អនុក្រឹត្យលេខ ៣០៦ អនក្រ.តត ស្តីពីការបញ្ចប់ភារកិច្ចមន្ត្រីរាជការ ១៨៦៨

១៨-៧-២០០១ -អនុក្រឹត្យលេខ ៣០៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៦៩

១៨-៧-២០០១ -អនុក្រឹត្យលេខ ៣០៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៧០

២០-៧-២០០១ -អនុក្រឹត្យលេខ ៣០៩ អនក្រ.តត ស្តីពីការដាក់មន្ត្រីរាជការអោយចូល និវត្តន៍ ១៨៧១

២០-៧-២០០១ -អនុក្រឹត្យលេខ ៣១០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៨៧២

២០-៧-២០០១ -អនុក្រឹត្យលេខ ៣១១ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិ ជាកិច្ច បច្ឆាមរណៈ ១៨៧៣

២០-៧-២០០១ -អនុក្រឹត្យលេខ ៣១២ អនក្រ.តត ស្តីពីការតែងតាំងផ្លាស់ប្តូរមុខតំណែង នាយហាន ១៨៧៤

២០-៧-២០០១ -អនុក្រឹត្យលេខ ៣១៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៧៥

## ២_សេចក្តីសំរេច

២៣-៧-២០០១ -សេចក្តីសំរេចលេខ ៤១ សសរ ស្តីពីការបង្កើតគណៈកម្មការ ដើម្បីស្រាវ ជ្រាវវត្ថុបុរាណ ដែលបានកប់ទុកក្នុងបរិវេណមន្ទីរវប្បធម៌ ខេត្តបាត់ដំបង ១៨៧៦

## ១_ទីស្តីការរដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### ប្រកាស

១៨-៧-២០០១ -ប្រកាសលេខ ៤៥៨ សហវ.ពដ ស្តីពីការកំណត់មូលដ្ឋានគិតអាករលើតម្លៃ បន្ថែមលើការ ដឹកជញ្ជូនទំនិញ ឬអ្នកដំណើរ ១៨៧៨

## ២_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស

១៨-៧-២០០១ -ប្រកាសលេខ ៤៥៨ ឧរថ ឧកស.ប្រក អនុញ្ញាតអោយលោក **សុខ គន់** ជនជាតិខ្មែរ បន្តដំណើរការសហគ្រាសធុនតូច កាត់ដេរសំលៀកបំពាក់ ១៨៨៤

១៩-៧-២០០១ -ប្រកាសលេខ ៤៧៣ ឧរថ.ឧកស.ប្រកអនុញ្ញាតអោយលោក **ឆែ ឡឿន** ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មកែច្នៃ ប្រេងរំអិល ១៨៨៥

## ៣_ទីស្តីការរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### ប្រកាស

១៧-៧-២០០១ -ប្រកាសលេខ ១៧៧ បទ.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៨៦

១៧-៧-២០០១ -ប្រកាសលេខ ១៧៨ បទ.ប្រក ស្តីពីការចាត់តាំងប្រព័ន្ធវិទ្យុគមនាគមន៍ សំរាប់គណៈ

កម្មាធិការជាតិរៀបចំការបោះឆ្នោត ១៨៨៨

១៩-៧-២០០១ -ប្រកាសលេខ ១៨១ បទ.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ មជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និងប័ណ្ណស័ព្ទ ១៨៩១

## ៤.ទីស្តីការរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី និងអតីត យុទ្ធជន

### ប្រកាស

១៩-៧-២០០១ -ប្រកាសលេខ ៤៧៤ កកនអ.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៩៦

## ៥.ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

### សេចក្តីសំរេច

១៨-៧-២០០១ -សេចក្តីសំរេចលេខ ២០៥ កធស.សរ ប្រកាសបិទចោលទាំងស្រុងចំពោះ សេចក្តីសំរេចលេខ ២៨ កធស.សរ ចុះថ្ងៃទី ១៩-០២-២០០១ ១៨៩៧

១៩-៧-២០០១ -សេចក្តីសំរេចលេខ ២០៦ កធស.សរ អនុញ្ញាតអោយបើកណាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " គ្រិស្តបរិស័ទបាប់ទីស្ទ ត្រពាំងកោះ " ស្ថិតនៅ ភូមិត្រពាំងកោះ ឃុំត្រពាំងធំ ខាងត្បូង ស្រុក ត្រាំកក់ ខេត្តតាកែវ ១៨៩៨

១៩-៧-២០០១ -សេចក្តីសំរេចលេខ ២០៧កធស.សរ អនុញ្ញាតអោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " ក្រុមជំនុំភូមិក្រញ្ចូង " ស្ថិតនៅភូមិ ក្រញូង ឃុំ មុខដា ស្រុករមាសហែក ខេត្តស្វាយរៀង ១៨៩៩

១៩-៧-២០០១ -សេចក្តីសំរេចលេខ ២០៨ កធស.សរ អនុញ្ញាតអោយបើកសាខាស្នាក់ការ ថ្វាយបង្គំ ព្រះគ្រិស្តឈ្មោះ " ប្រាសាទ " ស្ថិតនៅភូមិប្រាសាទ ឃុំឈូក ស្រុក ប្រាសាទសំបូរ ខេត្តកំពង់ធំ ១៩០០

១៩-៧-២០០១ -សេចក្តីសំរេចលេខ ២០៩ កធស.សរ អនុញ្ញាតអោយបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " ក្រុមជំនុំភូមិត្រពាំងស្នាច់ " ស្ថិតនៅភូមិត្រពាំង ស្នាច់ ឃុំ ជ្រៃធំ ស្រុករមាសហែក ខេត្តស្វាយរៀង ១៩០១

២០-៧-២០០១ -សេចក្តីសំរេចលេខ ២១០ កធស.សរ អនុញ្ញាតអោយបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " ក្រុមជំនុំគ្រិស្តបរិស័ទបាប់ទីស្ទស្វាយតានី " ស្ថិតនៅឃុំ ព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ១៩០២

២០-៧-២០០១ -សេចក្តីសំរេចលេខ ២១១ កធស.សរ អនុញ្ញាតអោយបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្តឈ្មោះ ក្រុមជំនុំបរិស័ទបាប់ទីស្ទប្រធាតុ " ស្ថិតនៅក្នុងឃុំ ស្រម៉រ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ១៩០៣

២០-៧-២០០១ -សេចក្តីសំរេចលេខ ២១២ កធស.សរ អនុញ្ញាតអោយបើកសាខាស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " គ្រិស្តបរិស័ទបាប់ទីស្ទភ្លើងឆេះរទេះ " ស្ថិតនៅ ភូមិភ្លើងឆេះរទេះ ឃុំភ្លើងឆេះរទេះ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ១៩០៤

២០-៧-២០០១ -សេចក្តីសំរេចលេខ ២១៣ កធស.សរ អនុញ្ញាតអោយបើកសាខាស្នាក់ ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " ល្វាអែ " ស្ថិតនៅក្នុងឃុំ ស្វាយដង្គំ ស្រុក សៀមរាប ខេត្តសៀមរាប ១៩០៥

# ព្រះរាជក្រឹត្យ

នស / រកត /០៧០១/២៣៤

ស្តីពី

## ការបង្កើត និង ការប្រព្រឹត្តទៅនៃ សហគមន៍អភិវឌ្ឍន៍កសិកម្ម សហភាពសហគមន៍អភិវឌ្ឍន៍កសិកម្ម និង បុរសហគមន៍អភិវឌ្ឍន៍កសិកម្ម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០០១ ៗ.រ.

# គ្រោងបន្ទាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .–**

ព្រះរាជក្រឹត្យនេះមានគោលដៅកំណត់អំពីការបង្កើត និង ការប្រព្រឹត្តទៅនៃសហគមន៍អភិវឌ្ឍន៍កសិកម្ម សហភាពសហគមន៍អភិវឌ្ឍន៍កសិកម្ម និង បុរេសហគមន៍អភិវឌ្ឍន៍កសិកម្ម ដែលហៅកាត់ថា " **សហគមន៍កសិកម្ម** "។ ដែនសកម្មភាពនៃសហគមន៍ទាំងបីនេះ មានវិសាលភាពគ្រងដណ្តប់លើវិស័យកសិកម្មទាំងមូល ទាំងការផ្គត់ផ្គង់សម្ភារៈ និង សេវាគ្រប់ប្រភេទ សម្រាប់បំរើមធ្យោបាយផលិតកម្មកសិកម្ម។

## ជំពូកទី២

## សហគមន៍កសិកម្ម

### ផ្នែកទី១

### និយមន័យ និង ការបង្កើត

**មាត្រា ២ .–**

សហគមន៍កសិកម្ម ដែលចែងក្នុងព្រះរាជក្រឹត្យនេះ ជានីតិបុគ្គលឯកជន ដែលមានដើមទុនអាចប្រែប្រួលបាន ហើយដែលមានសមត្ថភាពគតិយុត្តិពេញទី មានស្វ័យភាពហិរញ្ញវត្ថុ និង ការគ្រប់គ្រង ។

សហគមន៍កសិកម្ម អាចបង្កើតឡើងដោយរូបវន្តបុគ្គលមួយក្រុម ដែលប្រមូលផ្តុំគ្នាដោយស្ម័គ្រចិត្ត និង ដោយមានគំនិតផ្តួចផ្តើមផ្ទាល់ ដើម្បីបង្កើនផលិតភាពរបស់ខ្លួន និងរួមចំណែកក្នុងការលើកដំកើងសេដ្ឋកិច្ច និង សង្គមកិច្ច ។

ដូច្នេះតាមន័យនៃព្រះរាជក្រឹត្យនេះ សហគមន៍កសិកម្ម ជាសហគ្រាសសេដ្ឋកិច្ច ដែលគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ ដោយសមាជិករបស់ខ្លួន ដែលបានរួមចំណែកក្នុងដើមទុន និងសង្ឃឹមលើផល ព្រមទាំងសុខចិត្តទទួលគ្រោះខាតបង់ ស្របតាមសមាមាត្រភាគហ៊ុន ដែលបានចូលរួម ។

អាចចូលជាសមាជិកនៃសហគមន៍កសិកម្មបាន គ្រប់ជនទាំងឡាយ ដែលមានមុខរបរចំបង ស្ថិតនៅក្នុងវិស័យកសិកម្ម ឬ សេវាទាំងឡាយ ដែលមានទំនាក់ទំនងនឹងវិស័យកសិកម្ម ។

ព្រះរាជក្រឹត្យនេះ មិនគ្របដណ្តប់ទៅលើបណ្តាអង្គការ សមាគម ឬ ស្ថាប័នប្រហាក់ប្រហែល ដែលមិនចូលក្នុងនិយមន័យដូចបានបញ្ជាក់ខាងលើនេះឡើយ ហើយមិនស្ថិតនៅក្រោមច្បាប់ស្តីអំពីពាណិជ្ជកម្មឡើយ។

**មាត្រា ៣ .–**

ចំនួនរូបវន្តបុគ្គលយ៉ាងតិច ៣០នាក់ អាចបង្កើតសហគមន៍កសិកម្មមួយបាន ។ ដើម្បីករកើតបានសហគមន៍កសិកម្ម ត្រូវមានលក្ខន្តិកៈរបស់ខ្លួន ហើយត្រូវមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ ។ល។

មាត្រា ៤ .—

នៅក្នុងលក្ខន្តិកៈសហគមន៍កសិកម្មត្រូវបញ្ជាក់ពីនិទ្ទេសដូចតទៅ :

- នាមករណ៍
- ទីស្នាក់ការ និង អាសយដ្ឋាន
- កម្មវត្ថុ
- ល័ក្ខខ័ណ្ឌនៃការសុំចូលជាសមាជិក
- ភាគហ៊ុននីមួយៗត្រូវមានតម្លៃស្មើគ្នា
- ល័ក្ខខ័ណ្ឌនៃការបង់ប្រាក់ភាគហ៊ុន
- កាតព្វកិច្ច និង សិទ្ធិសមាជិក
- ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់សមាជិកចំពោះបំណុលរបស់សហគមន៍ ដែលយ៉ាងហោចមានកម្រិតស្មើនឹងចំនួនភាគហ៊ុនដែលខ្លួនបានជាវ ក្នុងករណីណាក៏ដោយ ប្រាក់បំណុលនេះពុំអាចឱ្យមានកម្រិតលើសពីដប់ (១០)ដងនៃចំនួន ភាគហ៊ុនដែលខ្លួនបានជាវនេះដែរ
- លក្ខណៈវិនិច្ឆ័យ និង ល័ក្ខខ័ណ្ឌនៃការលាឈប់ និង ការបណ្តេញចេញនៃសមាជិក
- របៀបរបបនៃការកាន់បញ្ជី និង ឯកសារនានា
- ល័ក្ខខ័ណ្ឌនៃការកោះប្រជុំមហាសន្និបាត
- សមាសភាពនៃក្រុមប្រឹក្សាភិបាល
- ល័ក្ខខ័ណ្ឌនៃការកោះប្រជុំក្រុមប្រឹក្សាភិបាល
- សមាសភាពនៃគណៈកម្មាធិការត្រួតពិនិត្យ
- ល័ក្ខខ័ណ្ឌនៃការកោះប្រជុំគណៈកម្មាធិការត្រួតពិនិត្យ
- ល័ក្ខខ័ណ្ឌនៃការផ្តល់ហិរញ្ញប្បទានដល់សហគមន៍កសិកម្ម និង លក្ខណៈវិនិច្ឆ័យសម្រាប់ប៉ាន់តម្លៃហិរញ្ញប្បទាននោះ
- ល័ក្ខខ័ណ្ឌនៃការរំលាយដោយសហគមន៍
- នីតិវិធីនៃមជ្ឈត្តវិនិច្ឆ័យ
- នីតិវិធីនៃការកែប្រែលក្ខន្តិកៈ

លក្ខន្តិកៈគំរូ និង បទបញ្ជាផ្ទៃក្នុងគំរូនៃសហគមន៍ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មាត្រា ៥ .—

ដើម្បីទទួលបានបុគ្គលិកលក្ខណៈគតិយុត្តិ សហគមន៍កសិកម្ម ត្រូវមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច ហើយមានចុះលេខក្នុងបញ្ជីតម្កល់ទុកនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-ក្រុង ។ ការទទួលស្គាល់នេះ ត្រូវបានបញ្ជាក់ដោយ៖

ការចេញវិញ្ញាបនប័ត្រ មានលេខចុះបញ្ជីរបស់សហគមន៍ និងត្រូវបានផ្សព្វផ្សាយទូលំទូលាយក្នុងរយៈពេល ( ០២ )ពីរសប្តាហ៍យ៉ាងច្រើន។ ការសុំលេខទទួលស្គាល់ ត្រូវបំពេញតាមនីតិវិធីដូចតទៅ :

១- ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ គិតចាប់ពីថ្ងៃប្រជុំសន្និបាតកំណើតដំបូង ក្រុមប្រឹក្សាភិបាលនៃសហគមន៍កសិកម្ម ត្រូវដាក់ពាក្យសុំការយល់ព្រមពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្ត-ក្រុង ដោយមានភ្ជាប់ជាមួយនូវពាក្យសុំ និងលិខិតផ្សេងៗ ដូចតទៅ :

- លក្ខន្តិកៈសហគមន៍ ដែលមានចុះ ថ្ងៃ ខែ និង មានហត្ថលេខា ឬស្នាមមេដៃនៃសមាជិកអ្នកបង្កើត..................ពីរច្បាប់
- របាយការណ៍នៃសន្និបាតកំណើតដំបូង ដែលមានហត្ថលេខា ឬ ស្នាមមេដៃនៃសមាជិកអ្នកបង្កើតទាំងអស់........មួយច្បាប់
- បញ្ជីសមាជិកក្រុមប្រឹក្សាភិបាល ឬ គណៈកម្មាធិការត្រួតពិនិត្យ ដោយបញ្ជាក់ពីឈ្មោះអាសយដ្ឋាន និង មុខងារម្នាក់ៗ..........................................................................................................មួយច្បាប់
- ហត្ថលេខា ឬ ស្នាមមេដៃសំណាករបស់អ្នកដែលមានសិទ្ធិតំណាងសហគមន៍............................................មួយច្បាប់
- ភស្តុតាងនៃការទទួលជាវភាគហ៊ុន និង ការបង់ប្រាក់ដោយសមាជិកនីមួយៗ..........................................មួយច្បាប់

២- ក្រោយពេលដែលបានទទួលពាក្យសុំ ដែលភ្ជាប់មកជាមួយនូវលិខិតផ្សេងៗ ដូចរៀបរាប់ខាងលើ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-ក្រុង ត្រូវចេញបង្កាន់ដៃទទួលពាក្យ បញ្ជាក់ពី ថ្ងៃ ខែ និង ហត្ថលេខាមន្ត្រីទទួលខុសត្រូវ ក្រោយពីពិនិត្យឃើញថា ពាក្យសុំបានបំពេញ លក្ខខណ្ឌតាមព្រះរាជក្រឹត្យនេះ ហើយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-ក្រុង ត្រូវចេញវិញ្ញាបនប័ត្រទទួលស្គាល់ ដែលមានលេខចុះបញ្ជី ក្នុងរយៈពេលមិនហួសពី (៤៥) សែសិបប្រាំថ្ងៃ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃ។

## ផ្នែកទី២
## ភារកិច្ច និងសិទ្ធិ របស់សហគមន៍កសិកម្ម និងសមាជិក

**មាត្រា ៦ .-**

សហគមន៍កសិកម្ម ត្រូវរក្សាទុកនៅក្នុងទីស្នាក់ការរបស់ខ្លួន នូវលក្ខន្តិកៈមួយច្បាប់ដែលត្រូវបានទទួល ហើយនៅជាធរមាន ។

លើសពីនេះសហគមន៍កសិកម្មត្រូវកាន់ :

- បញ្ជីសមាជិក និង ភាគហ៊ុននៃសមាជិក
- បញ្ជីកំណត់ហេតុអង្គប្រជុំមហាសន្និបាត ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការត្រួតពិនិត្យ និង អង្គភាពដទៃទៀត ដែលមហាសន្និបាតបានបង្កើតឡើង ព្រមទាំងបញ្ជីដទៃទៀតដែលមានចែងក្នុងលក្ខន្តិកៈ ។

សមាជិកសហគមន៍កសិកម្ម ឬអ្នកដែលទទួលបន្ទុកជាផ្លូវការក្នុងការត្រួតពិនិត្យ អាចឆែកមើលបញ្ជីទាំងនោះនៅពេលណាក៏បាន ។

នៅក្នុងពេលប្រតិបត្តិការជាមួយតតិយជន សហគមន៍កសិកម្មត្រូវបង្ហាញលេខចុះបញ្ជីរបស់ខ្លួន ដូចមានចែងនៅ...

—

មាត្រា៥។

**មាត្រា ៧ .–**

សហគមន៍កសិកម្មត្រូវស្ថិតនៅក្រោមចំណុះបទប្បញ្ញត្តិជាធរមានស្តីពីសវនកម្មនិងការត្រួតពិនិត្យពីខាងក្រៅ ។ សវនកម្មសហគមន៍កសិកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨ .–**

តាមរយៈការដាក់ពាក្យសុំចូលជាសមាជិក សមាជិកនីមួយៗត្រូវសុខចិត្តគោរពបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ ព្រមទាំងលក្ខន្តិកៈ និង សេចក្តីសម្រេចនានារបស់មហាសន្និបាតនៃសហគមន៍កសិកម្ម ។

សមាជិកទាំងឡាយត្រូវបង់ប្រាក់ភាគហ៊ុន ដែលខ្លួនបានជាវឱ្យស្របតាមល័ក្ខខ័ណ្ឌ ដូចមានចែងក្នុងលក្ខន្តិកៈ ។ សមាជិកទាំងឡាយត្រូវទទួលខុសត្រូវរៀងៗខ្លួនផង និង រួមគ្នាផង ចំពោះបំណុលរបស់សហគមន៍កសិកម្ម ក្នុងកម្រិតព្រំដែន ដូចមានចែងក្នុងលក្ខន្តិកៈ។ ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុនេះ ជាការទទួលខុសត្រូវរបស់សមាជិក ចំពោះសហគមន៍កសិកម្មរបស់ខ្លួន ។

**មាត្រា ៩ .–**

១- យោងតាមមាត្រា ៨ ខាងលើ សមាជិកណាដែលបានបំពេញល័ក្ខខ័ណ្ឌគ្រប់គ្រាន់ ជាមួយសហគមន៍កសិកម្មរបស់ខ្លួន មានសិទ្ធិ :

- ចូលរួមប្រជុំមហាសន្និបាត និង បោះឆ្នោតស្មើភាពគ្នា ជាមួយនឹងសមាជិកដទៃទៀត ដោយពុំគិតពីកម្រិតដើមទុនដែលបានវិនិយោគក្នុងសហគមន៍កសិកម្មឡើយ
- បោះឆ្នោត និង ឈរឈ្មោះក្នុងរចនាសម្ព័ន្ធសហគមន៍កសិកម្ម ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ
- ទទួលពត៌មានអំពីស្ថានភាពសេដ្ឋកិច្ចរបស់សហគមន៍ពីប្រធាន ឬ គណៈកម្មាធិការត្រួតពិនិត្យ
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និង សម្រេចលើបញ្ហាណាមួយបើមានការស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី(១/៣) នៃសមាជិកទាំងអស់
- ធ្វើសំណូមពរឱ្យដាក់ចូលរបៀបវារៈនៃមហាសន្និបាត នូវបញ្ហាទាំងឡាយដែលមានប្រយោជន៍សម្រាប់សហគមន៍
- ទទួលភាគចំណេញរៀងៗខ្លួន
- ជួលប្រើប្រាស់សេវា សំណង់ និងគ្រឿងឧបករណ៍នានារបស់សហគមន៍ ដូចគ្នានឹងសមាជិកដទៃទៀតទាំងអស់
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍
- ទទួលបានស្របតាមលក្ខន្តិកៈនូវភាគហ៊ុន ដែលបានបង់គ្រប់ចំនួន ហើយបូកនឹងការប្រាក់ ឬប្រាក់បង្វិលសងវិញនៅពេលដែលសមាជិកសុំលាលែង ឬ ត្រូវគេបណ្តេញចេញ ឬ ក្នុងករណីសល់ពីការខាតបង់របស់សហគមន៍តាមសមាមាត្រនៃការខាតបង់

២- ផ្ទុយទៅវិញ សមាជិកណាមួយ ដែលមានការយឺតយ៉ាវក្នុងការបង់ប្រាក់ ដែលតម្រូវដោយលក្ខន្តិកៈ ឬពុំបានគោរពនូវ ៗ.ល.

ភារកិច្ចរបស់ខ្លួនចំពោះសហគមន៍ សមាជិកនោះពុំអាចចូលរួមធ្វើសេចក្តីសម្រេច ឬ ទទួលប្រាក់ចំណេញពីសហគមន៍បានឡើយ ។

**មាត្រា ១០ .—**

ក្នុងករណីដែលមានសមាជិកសហគមន៍ណាម្នាក់ ធ្វើឱ្យមានការប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍នៃសហគមន៍ ឬ សមាជិកសហគមន៍ដទៃទៀត សមាជិករូបនោះអាចត្រូវបានគេព្យួរ ឬ ក៏ត្រូវបានគេបណ្តេញចេញពីសហគមន៍ ក្រោយពីបានការពារខ្លួននៅចំពោះមុខក្រុមប្រឹក្សាភិបាល ។

ការព្យួរ ឬ ការបណ្តេញចេញត្រូវសម្រេចដោយមហាសន្និបាត ។ ក្នុងករណីមានការប្រញាប់ ក្រុមប្រឹក្សាភិបាលអាចប្រកាសជាបណ្តោះអាសន្ននូវការព្យួរ ឬ ការបណ្តេញចេញបាន តែត្រូវមានកោះប្រជុំមហាសន្និបាតវិសាមញ្ញជាបន្ទាន់ ដើម្បីពិភាក្សា និងសម្រេចលើបញ្ហានេះ ។

## ផ្នែកទី៣
## រចនាសម្ព័ន្ធរបស់សហគមន៍ និងភារកិច្ច

**មាត្រា ១១ .—**

សន្និបាតកំណើតដំបូងរបស់សហគមន៍ ដែលមានការចូលរួមពីរូបវន្តបុគ្គលជាអ្នកបង្កើតទាំងអស់គ្នា មាននាទីរៀបចំឯកសារដែលមានភ្ជាប់ពាក្យសុំទទួលស្គាល់ និង ធ្វើសេចក្តីសម្រេចនានា ដែលបានតម្រូវដើម្បីដាក់ឱ្យដំណើរការនៃការិយបរិច្ឆេទសង្គមទីមួយ ។

មហាសន្និបាតជាអង្គការកំពូល និង ខ្ពស់បំផុតសម្រាប់ធ្វើការអនុម័ត និង ធ្វើសេចក្តីសម្រេចចិត្តទាំងឡាយ ក្នុងនាមសហគមន៍ ។

សមាជិកទាំងអស់ ត្រូវចូលរួមប្រជុំមហាសន្និបាតសាមញ្ញមួយឆ្នាំម្តង ដែលត្រូវប្រារព្ធក្នុងរយៈពេលបីខែយ៉ាងយូរ ក្រោយការបិទការិយបរិច្ឆេទមុន ។

ការកោះប្រជុំមហាសន្និបាតត្រូវបញ្ជាក់ពីទីកន្លែង ថ្ងៃ ខែ ម៉ោង និង របៀបវារៈ ។ សមាជិកសហគមន៍ត្រូវ ឱ្យបានដឹងពីកិច្ចប្រជុំនេះ ( ១៥ ) ដប់ប្រាំថ្ងៃយ៉ាងតិច មុនថ្ងៃប្រជុំ ។ សេចក្តីជូនដំណឹង ត្រូវធ្វើតាមរបៀបផ្សព្វផ្សាយពតិមានធម្មតា ហើយត្រូវបិទប្រកាសនៅទីស្នាក់ការសហគមន៍ ។

សមាជិកសហគមន៍ ត្រូវរួមប្រជុំមហាសន្និបាតវិសាមញ្ញ ដែលកោះប្រជុំដោយប្រធាន ។

ការកោះប្រជុំមហាសន្និបាតវិសាមញ្ញត្រូវបញ្ជាក់ពីទីកន្លែង ថ្ងៃ ខែ ម៉ោង និង របៀបវារៈនៃកិច្ចប្រជុំ ។ សមាជិកសហគមន៍ ត្រូវទទួលដំណឹងពីកិច្ចប្រជុំនេះ (០៧) ប្រាំពីរថ្ងៃយ៉ាងតិច មុនថ្ងៃប្រជុំ ។ សេចក្តីជូនដំណឹង ត្រូវធ្វើតាមរបៀបផ្សព្វផ្សាយពតិមានធម្មតា ហើយត្រូវបិទប្រកាសនៅទីស្នាក់ការសហគមន៍ផង ។៚.

មាត្រា ១២ ._

មហាសន្និបាត :

- ផ្ដល់ការយល់ព្រមលើកំណត់ហេតុរបស់ក្រុមប្រឹក្សាភិបាល ឬ គណៈកម្មាធិការត្រួតពិនិត្យ
- អនុម័តទទួល ឬ កែប្រែលក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុង
- បោះឆ្នោតជ្រើសតាំង ក្នុងចំណោមសមាជិកសហគមន៍កសិកម្ម នូវប្រធាន សមាជិកដទៃទៀត របស់ក្រុមប្រឹក្សាភិបាល ព្រមទាំងសមាជិកគណៈកម្មាធិការត្រួតពិនិត្យ តាមការបោះឆ្នោតជាសម្ងាត់ ។ មហាសន្និបាតអាចដកតំណែងពីអ្នកដែលជាប់ឆ្នោតទាំងនោះវិញ និង កំណត់លាភការជូនអ្នកទាំងនោះ បើសិនជាមាន
- កំណត់ភារកិច្ចក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យ
- តែងតាំងអ្នកត្រួតពិនិត្យមកពីក្រៅម្នាក់ ឬ ច្រើននាក់ ហើយកំណត់អាណត្តិព្រមទាំងប្រាក់បំណាច់របស់គេ
- កំណត់កម្រិតអតិបរមានៃបំណុល ដែលសហគមន៍អាចខ្ចីបាន សម្រាប់កម្មវត្ថុរបស់ខ្លួនតែប៉ុណ្ណោះ ដោយរក្សាបានផងនូវស្វ័យភាពរបស់សហគមន៍
- អនុញ្ញាតការវិនិយោគ ឬ ការចងការមូលនិធិសហគមន៍
- កំណត់បែបបទ និងកំណត់ទឹកប្រាក់ដែលអនុញ្ញាតអោយសមាជិកខ្ចី
- ពិនិត្យផ្ដល់ការយល់ព្រម ឬ កែសម្រួលគណនី និង របាយការណ៍នៃការគ្រប់គ្រង ហើយនិងយល់ព្រម ឬ មិនយល់ព្រមឱ្យអ្នកគ្រប់គ្រងរួចខ្លួន
- ពិភាក្សា អនុម័តលើរបាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មាធិការត្រួតពិនិត្យ បន្ទាប់ពីបានសិក្សារួច
- កំណត់ការបែងចែកប្រាក់ចំណេញ និង ប្រាក់ដែលត្រូវប្រគល់ត្រឡប់ឱ្យសមាជិកវិញ ដោយអនុលោមតាម លក្ខណៈវិនិច្ឆ័យដែលកំណត់ដោយបទបញ្ជាផ្ទៃក្នុង
- ប្រាក់អតិរេកនៃឆ្នាំនីមួយៗអាចធ្វើទៅបាន លុះត្រាតែបានដាក់បញ្ចូលប្រាក់ ទៅក្នុងមូលនិធិបម្រុងតាមលក្ខន្តិកៈ ឬ ក្នុងមូលនិធិបន្ទាប់បន្សំ ព្រមទាំងទូទាត់បំណុលសហគមន៍នៃឆ្នាំកន្លងមកជាមុន
- កំណត់មូលនិធិត្រៀមបម្រុងសម្រាប់ការប៉ះប៉ូវការខាតបង់ ដែលអាចកើតឡើង
- ធ្វើឱ្យមានលំនឹងឡើងវិញ ចំពោះការបែងចែកភាគហ៊ុនទៅឱ្យសមាជិកនីមួយៗ ក្នុងករណីមានការថយចុះនូវ ចំនួនសមាជិក
- អនុម័តយល់ព្រមកម្មវិធីសកម្មភាព និង ថវិកាសម្រាប់ការិយបរិច្ឆេទខាងមុខ
- សម្រេចពីការសុំចូលជាសមាជិកថ្មី ការព្យួរ និង ការបណ្ដេញចេញសមាជិកនីមួយៗ
- សម្រេចពីការផ្លាស់ប្ដូរនានា ដូចជាការបំបែក ការរំលាយបញ្ចូលគ្នា និង ការរំសាយសហគមន៍ ។

មាត្រា ១៣ ._

មហាសន្និបាតអាចប្រជុំពិភាក្សា អនុម័ត និងសម្រេចបាន លុះត្រាតែមានវត្តមាន (២/៣) ពីរភាគបីនៃចំនួនសមាជិក ៩.т.

សហគមន៍កសិកម្ម ។ ក្នុងករណីដែលល័ក្ខខ័ណ្ឌខាងលើពុំអាចបំពេញបាន ការកោះប្រជុំមហាសន្និបាតជាលើកទីពីរ ដោយមានរបៀបវារៈដូចគ្នានឹងរបៀប វារៈទីមួយត្រូវធ្វើឡើងក្នុងរយៈពេល (១០) ដប់ថ្ងៃ បន្ទាប់ពីថ្ងៃកំណត់សម្រាប់កិច្ចប្រជុំលើកទីមួយ ។ កិច្ចប្រជុំលើកទីពីរនេះ ចំនួនសមាជិកវត្តមាន ពុំមានកំណត់ទេ ។

មហាសន្និបាតត្រូវដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល ឬ ដោយប្រធានអង្គប្រជុំ ជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមសមាជិកវត្តមាន ។ មហាសន្និបាត តែងតាំងលេខាធិការអង្គប្រជុំម្នាក់ ដែលធ្វើកំណត់ហេតុក្នុងនោះមានបញ្ជាក់អំពីសេចក្តីសម្រេច និង បញ្ជីសមាជិកវត្តមាន ។ លេខាធិការ និង ប្រធានអង្គប្រជុំ ត្រូវចុះហត្ថលេខាលើកំណត់ហេតុនេះ ។

សមាជិកម្នាក់មានសំឡេងតែមួយគត់នៅក្នុងមហាសន្និបាត ហើយមិនអាចបញ្ជូនមនុស្សមកជាតំណាងទេ ។ ចំពោះការបោះឆ្នោតជ្រើសរើសប្រធានអង្គប្រជុំ ត្រូវធ្វើឡើងតាមរបៀបបោះឆ្នោតសម្ងាត់ ។ វៀរលែងតែសេចក្តីសម្រេចដែលទាក់ទងនឹងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ធ្វើបដិរូបសហគមន៍ ឬ ការបណ្តេញចេញសមាជិកណាមួយ ដែលតម្រូវឱ្យមានការយល់ព្រមពីពីរភាគបី (២/៣) នៃសមាជិកវត្តមាន សេចក្តីសម្រេចផ្សេងៗទៀតរបស់មហាសន្និបាត ត្រូវយកសម្លេងភាគច្រើននៃសមាជិកវត្តមាន ។

សមាជិកសហគមន៍កសិកម្មទាំងអស់ ត្រូវទទួលខុសត្រូវចំពោះសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត ។

## មាត្រា ១៤ .–

ក្រុមប្រឹក្សាភិបាលជាអង្គការប្រតិបត្តិរបស់សហគមន៍ ។ ប្រធានព្រមទាំងសមាជិកដទៃទៀតនៃក្រុមប្រឹក្សាភិបាល ត្រូវបានបោះឆ្នោតជ្រើសរើសដោយមហាសន្និបាត ។ សមាសភាពរបស់ក្រុមប្រឹក្សាភិបាល មានសមាជិកចាប់ពី បី ( ០៣ ) ទៅប្រាំបួន ( ០៩ ) នាក់ ដោយរាប់បញ្ចូលទាំងប្រធានផង ។ នាមហាសន្និបាតទីមួយ មួយភាគបី( ១/៣ ) នៃចំនួនសមាជិកក្រុមប្រឹក្សា-ភិបាលត្រូវបានជ្រើសតាំង សម្រាប់អាណត្តិមួយឆ្នាំ ( ០១ ) មួយភាគបី( ១/៣ ) ទៀតសម្រាប់ពីរ ( ០២ ) ឆ្នាំ និងមួយភាគបី( ១/៣ ) ចុងក្រោយសម្រាប់បី( ០៣ ) ឆ្នាំ។ ឪពុកម្តាយ បងប្អូនបង្កើត បងប្អូនជីដូនមួយ ប្តីប្រពន្ធ ពុំអាចធ្វើជាសមាជិកក្រុមប្រឹក្សាភិបាលជាមួយគ្នាបានទេ។ ក្រុមប្រឹក្សាភិបាលត្រូវបាន បោះឆ្នោត ជ្រើសរើសសម្រាប់អាណត្តិបី ( ០៣ ) ឆ្នាំ ហើយមិនអាចត្រូវបានជ្រើសរើសហួសពីពីរ ( ០២ ) អាណត្តិជាប់គ្នាឡើយ ។

ក្រុមប្រឹក្សាភិបាលជ្រើសរើសដោយការបោះឆ្នោតជាសម្ងាត់នូវហិរញ្ញិកម្នាក់ និងលេខាធិការម្នាក់ ក្នុងចំណោមសមាជិករបស់ខ្លួន តែបើក្នុងចំណោមសមាជិកមិនអាចរើសបាន អាចជ្រើសរើសបន្ថែមបាន ។

ប្រធានក្រុមប្រឹក្សាភិបាល ជាអ្នកតំណាងសហគមន៍ និងជាអ្នកកោះប្រជុំក្រុមប្រឹក្សាភិបាលយ៉ាងតិចពីរ( ០២ ) ខែម្តង ។

ក្រុមប្រឹក្សាភិបាលអាចត្រូវកោះប្រជុំបានតាមសំណើរបស់សមាជិកភាគច្រើននៃក្រុមប្រឹក្សានេះ ។

ក្រុមប្រឹក្សាភិបាលអាចធ្វើការប្រជុំបាន លុះត្រាតែមានវត្តមានពាក់កណ្តាល (១/២) នៃសមាជិករបស់ខ្លួន ។ សេចក្តីសម្រេចចិត្តដែលទុកជាបានការ គឺភាគច្រើនដាច់ខាតនៃសមាជិកវត្តមាន ។

ក្នុងករណីដែលចំនួនសំឡេងចែកជាពីរ ( ០២ ) ស្មើគ្នា សំឡេងរបស់ប្រធានមានឧត្តមានុភាព ។

នាយកគ្រប់គ្រងម្នាក់ អាចត្រូវបានជ្រើសរើសពីបុគ្គលិកមានបៀវត្ស ដោយក្រុមប្រឹក្សាភិបាល ។ នាយកគ្រប់គ្រងមានភារកិច្ចជួយក្រុមប្រឹក្សាភិបាល ក្នុងកិច្ចការគ្រប់គ្រងសហគមន៍ និង ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ដោយមានសំឡេងត្រឹមតែផ្តល់យោបល់ ។ ៸.ត.

សមាជិកគណៈកម្មាធិការត្រួតពិនិត្យ អាចចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ដោយមានសំឡេងត្រឹមតែផ្តល់យោបល់ ។

**មាត្រា ១៥ .–**

១- សិទ្ធិ :

- ក្នុងកម្រិតព្រំដែននៃព្រះរាជក្រឹត្យនេះ លក្ខន្តិកៈ និង សេចក្តីសម្រេចនានានៃមហាសន្និបាត ក្រុមប្រឹក្សាភិបាលទទួលអំណាចទូលំទូលាយក្នុងកិច្ចការដឹកនាំ និង ការគ្រប់គ្រងសហគមន៍ ។

២-ភារកិច្ច :

ក្រុមប្រឹក្សាភិបាល មានភារកិច្ចជាអាទិ៍ :

- កាន់ ឬ បញ្ជាឱ្យកាន់បញ្ជីសមទិន ព្រមទាំងធ្វើយ៉ាងណាឱ្យកិច្ចការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់សហគមន៍មានដំណើរស្របទៅនឹងទម្លាប់នានាជាធរមាន ។
- ត្រូវធ្វើគណនេយ្យភាព ដោយឡែកពីគ្នាចំពោះប្រតិបត្តិការជួញដូរជាមួយ និងសមាជិក និងជាមួយអ្នកដែលមិនមែនជាសមាជិកសហគមន៍
- រៀបចំ ការប្រជុំមហាសន្និបាត
- រាយការណ៍ជូនមហាសន្និបាតនូវរបាយការណ៍ ស្តីពីការគ្រប់គ្រងនៃការិយបរិច្ឆេទកន្លងទៅ ដែលមានរបាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាព តារាងតុល្យការ និងគណនីយអាជីវកម្ម ហើយនឹងកម្មវិធីសកម្មភាព ដែលរួមមានការបណ្តុះបណ្តាលសមាជិក និងបុគ្គលិកព្រមទាំងថវិកា គម្រោងមួយសម្រាប់ការិយបរិច្ឆេទខាងមុខ
- រៀបចំឯកសារចាំបាច់សម្រាប់ការត្រួតពិនិត្យ ដែលច្បាប់តម្រូវព្រមទាំងរាយការណ៍បង្ហាញជូនមហាសន្និបាត
- រៀបចំប្រជុំមហាសន្និបាតវិសាមញ្ញ នៅពេលណាដំណើរការរបស់សហគមន៍កសិកម្ម តម្រូវឱ្យមានការពិភាក្សាអនុម័ត ឬធ្វើ សេចក្តីសម្រេចណាមួយ ឬ ក៏តាមការស្នើសុំរបស់សមាជិកដោយអនុលោមតាមមាត្រា១៦ នៃព្រះរាជក្រឹត្យនេះ ។

៣- បន្ទាប់ពីសួរយោបល់គណៈកម្មាធិការត្រួតពិនិត្យ ក្រុមប្រឹក្សាភិបាលអាចតែងតាំងនាយកគ្រប់គ្រងម្នាក់ ដែលជាសមាជិក ឬមិនមែនសមាជិករបស់សហគមន៍ ។ នាយកគ្រប់គ្រងត្រូវគោរពតាមបទប្បញ្ញត្តិទាំងឡាយ ដែលមានចុះនៅ ក្នុងកិច្ចសន្យាជាលាយល័ក្ខអក្សរ ក្នុងការអនុវត្តភារកិច្ច ដែលក្រុមប្រឹក្សាភិបាលប្រគល់ឱ្យ ។ នាយកគ្រប់គ្រងអាចជ្រើសរើសបុគ្គលិកចាំបាច់ សម្រាប់ប្រសិទ្ធភាពនៃការគ្រប់គ្រងរបស់សហគមន៍ ។ កិច្ចសន្យារបស់បុគ្គលិកទាំងនោះ ត្រូវមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល និង ចំណេះច្បាប់ការងារ ។

**មាត្រា ១៦ .–**

សមាជិកក្រុមប្រឹក្សាភិបាល និង នាយកគ្រប់គ្រងត្រូវទទួលខុសត្រូវរៀងៗខ្លួន និងរួមគ្នាផង ចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញបេសកកម្ម ដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ។ល។

**មាត្រា ១៧ .—**

គណៈកម្មាធិការត្រួតពិនិត្យជាអង្គការត្រួតពិនិត្យអចិន្ត្រៃយ៍ផ្ទៃក្នុងរបស់សហគមន៍ ។ គណៈកម្មាធិការនេះ ធ្វើការសម្រាប់តែផលប្រយោជន៍របស់សហគមន៍តែម្យ៉ាង ។ ប្រធានគណៈកម្មាធិការត្រួតពិនិត្យ ត្រូវបោះឆ្នោតជ្រើសរើសពីក្នុងចំណោមសមាជិករបស់ខ្លួន ។ គណៈកម្មាធិការត្រួតពិនិត្យអាចព្យួរតួនាទីក្រុមប្រឹក្សាភិបាលបាន ។ ក្នុងករណីដែលក្រុមប្រឹក្សាភិបាលពុំព្រមធ្វើតាម ឬ ស្ថិតក្នុងអលទ្ធភាព ចំពោះការបំពេញកាតព្វកិច្ចរបស់ខ្លួន គណៈកម្មាធិការត្រួតពិនិត្យ អាចជំនួសបំពេញតួនាទីក្រុមប្រឹក្សាភិបាលបាន តែមិនឱ្យលើសពីបី ( ០៣ )ខែទេ ។ នៅក្នុងរយៈពេលនោះ គណៈកម្មាធិការត្រួតពិនិត្យត្រូវកោះប្រជុំ មហាសន្និបាតវិសាមញ្ញ ដើម្បីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលថ្មី ។

គណៈកម្មាធិការត្រួតពិនិត្យមានសមាជិកពីបី ( ០៣ ) ទៅប្រាំ ( ០៥ ) នាក់ ជាសមាជិក ដែលពុំមានឈ្មោះនៅក្នុងក្រុមប្រឹក្សាភិបាល ឬ បុគ្គលិកមានបៀវត្សរបស់សហគមន៍ឡើយ ។ បុគ្គលដែលត្រូវជាឪពុកម្ដាយ បងប្អូនបង្កើត បងប្អូនជីដូនមួយ ប្ដីប្រពន្ធ ជាមួយនឹង សមាជិកក្រុមប្រឹក្សាភិបាលពុំអាចធ្វើជា សមាជិកនៃគណៈកម្មាធិការត្រួតពិនិត្យបានទេ ។

អាណត្តិរបស់សមាជិកគណៈកម្មាធិការត្រួតពិនិត្យត្រូវកំណត់បី(០៣) ឆ្នាំ ។ សមាជិកម្នាក់ៗពុំអាចបម្រើការងារនេះលើសពីពីរ(០២) អាណត្តិជាប់គ្នាទេ ។ គណៈកម្មាធិការត្រួតពិនិត្យប្រជុំគ្នា តាមការកោះប្រជុំរបស់ប្រធាន នៅពេលដែលមានការចាំបាច់ ឬ តាមសំណូមពររបស់សមាជិកយ៉ាងតិចពីរ ( ០២ )នាក់ ។ ក្នុងករណីមានការចែកសំឡេងជាពីរស្មើគ្នា សំឡេងរបស់ប្រធានមានឧត្តមានុភាព ។

**មាត្រា ១៨ .—**

គណៈកម្មាធិការត្រួតពិនិត្យអាចឆែក ឬ បញ្ជាឱ្យគេឆែកសៀវភៅគណនេយ្យ ឯកសារ បញ្ជីបេឡា គណនី និងទ្រព្យសម្បត្តិរបស់សហគមន៍ ពេលណាក៏បាន ហើយនិងត្រួតពិនិត្យភាពត្រឹមត្រូវរបស់បញ្ជីសារពើភ័ណ្ឌ និង តារាងតុល្យការ ។

គណៈកម្មាធិការនេះ អាចធ្វើការត្រួតពិនិត្យលើអ្វីៗដែលចាំបាច់ទាំងអស់ ។ គណៈកម្មាធិការត្រួតពិនិត្យត្រូវជូនពត៌មានស្ដីពីសភាពការណ៍ដែលខ្លួនបានកត់សម្គាល់ទៅក្រុមប្រឹក្សាភិបាល ហើយនិងរៀបរាប់អំពីបញ្ហានេះ ក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនជូនទៅមហាសន្និបាត ។ ក្នុងករណីចាំបាច់ គណៈកម្មាធិការត្រួតពិនិត្យ ឬ ក្រុមប្រឹក្សាភិបាល ឬ មហាសន្និបាតវិសាមញ្ញត្រូវកោះប្រជុំ។

**មាត្រា ១៩ .—**

មុខងាររបស់សមាជិកក្រុមប្រឹក្សាភិបាល និង គណៈកម្មាធិការត្រួតពិនិត្យមិនមានប្រាក់បំណាច់ទេ ។ ប៉ុន្តែមហាសន្និបាតអាចគ្រោងទុកនូវថវិកាសម្រាប់ទូទាត់ចំណាយ ដែលសមាជិកទាំងនេះបានចាយវាយ នៅពេលបំពេញមុខងារ ។៚

## ជំពូកទី៤
## ដើមទុន

**មាត្រា ២០ .–**

ប្រភពហិរញ្ញវត្ថុសហគមន៍រួមមាន :

- ភាគហ៊ុនដែលជាវ និង បង់ដោយសមាជិក
- មូលនិធិបម្រុងដែលដកចេញពីប្រាក់អតិរេក
- អំណោយ កេរមរតក ឬ វិភាគទានដែលត្រូវបញ្ចូលក្នុងទ្រព្យសម្បត្តិរបស់សហគមន៍ ហើយដាក់ក្នុងគណនេយ្យដោយឡែក
- កម្ចីពីតតិយជន
- កម្ចីពីសមាជិកដែលមានរូបភាពជាប្រាក់តម្កល់ ឬ ជាប្រាក់សន្សំ

**មាត្រា ២១ .–**

ដើមទុនរបស់សហគមន៍ ប្រែប្រួលទៅតាមការកើនឡើង បណ្តាលមកពីការចូលថែមនៃសមាជិកថ្មី ឬ ការជាវភាគហ៊ុនបន្ថែម ។ ការថយចុះនៃដើមទុន បណ្តាលមកពីការសងទៅវិញ នៅពេលដែលមានការដកភាគហ៊ុន ។

**មាត្រា ២២ .–**

ភាគហ៊ុនមានឈ្មោះ មិនអាចបំបែក មិនអាចរឹបអូសដោយតតិយជន មិនអាចលក់បានទេ បានតែផ្ទេរពីសមាជិកម្នាក់ទៅសមាជិកម្នាក់ទៀតរបស់សហគមន៍ ឬ ទៅអ្នកទទួលកេរមរតកពីសមាជិក អនុលោមទៅតាមច្បាប់ជាធរមាន និងក្រោយពីមានឯកភាពពីក្រុមប្រឹក្សាភិបាលស្របតាមលក្ខន្តិកៈ ។ តម្លៃរបស់ភាគហ៊ុន ត្រូវបានកំណត់ដោយលក្ខន្តិកៈ ដែលអាចកំណត់ជាមុនអំពីពេលត្រូវបង់ តែមួយដង ឬ ច្រើនដង ។

ភាគហ៊ុនដែលពុំទាន់បានបង់គ្រប់ ពុំមានសិទ្ធិទទួលប្រាក់ចំណេញទេ ។ ចំណែកភាគហ៊ុនដែលបានបង់ប្រាក់ហើយ ក្នុងករណីដែលមានប្រាក់ចំណេញ អាចទទួលបានការប្រាក់ ដែលមានអត្រាមិនលើសពីអត្រាការប្រាក់ ដែលធនាគារពាណិជ្ជកម្មផ្តល់ឱ្យចំពោះគណនីសញ្ញ័យរយៈពេលវែង ។

សមាជិកម្នាក់ពុំអាចមានភាគហ៊ុនលើសពីម្ភៃភាគរយ ( ២០% ) នៃចំនួនភាគហ៊ុនសរុបបានទេ ។

**មាត្រា ២៣ .–**

រាល់សហគមន៍ត្រូវបង្កើតមូលនិធិបម្រុងមួយដែលថ្ងាប់តម្រូវ ដោយដកយកម្ភៃភាគរយ ( ២០% ) ពីប្រាក់អតិរេកសុទ្ធក្រោយពីបានបង់ពន្ធរហូតដល់ប្រាក់បម្រុងនេះ មានចំនួនប្រាំ ( ០៥ ) ដងនៃចំនួនភាគហ៊ុនទាំងអស់ ដែលបានបង់ហើយ ។ ៗ.

ប្រាក់ចំណេញដែលបានមកពីប្រតិបត្តិការ ជួញដូរជាមួយអ្នកដែលមិនមែនសមាជិក ត្រូវបញ្ចូលមកក្នុងមូលនិធិបម្រុងនេះដែរ ។

សហគមន៍ទាំងអស់ ត្រូវបង្កើតមូលនិធិសម្រាប់វគ្គបណ្តុះបណ្តាល អប់រំសមាជិកអ្នកគ្រប់គ្រង និង អ្នកដឹកនាំអង្គការគ្រប់គ្រងព្រមទាំងបុគ្គលិក ដោយដកយកពីប្រាក់អតិរេកសុទ្ធចំនួនបីភាគរយ ( ៣% )ក្នុងមួយឆ្នាំ ។ មូលនិធិបម្រុងមិនអាចយកទៅចែកចាយឱ្យសមាជិកបានទេ ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ________

## ជំពូកទី៥

## បដិរូបកម្ម ជំរះលោះស្រាយទីធាន

**មាត្រា ២៤ .-**

មហាសន្និបាតនៃសហគមន៍កសិកម្ម អាចរំលាយសហគមន៍បញ្ចូលគ្នាជាមួយសហគមន៍មួយឬច្រើនទៀតបាន តាមរយៈការស្រូបយកសហគមន៍មួយទៀត ឬតាមរយៈការរួបរួមគ្នាបង្កើតសហគមន៍ថ្មីមួយទៀត ។

ក្រុមប្រឹក្សាភិបាលនៃសហគមន៍សាមីនីមួយៗ ត្រូវជូនពត៌មានទៅម្ចាស់បំណុលទាំងអស់អំពីគម្រោងការបញ្ចូលគ្នានិងគម្រោងការទូទាត់បំណុល ។ ម្ចាស់បំណុលមានរយៈពេលបី ( ០៣ )ខែ ដើម្បីស្នើសុំទៅតុលាការមានសមត្ថកិច្ច ឱ្យផ្អាកគម្រោងការបញ្ចូលរហូតដល់លក្ខខណ្ឌ ដែលតម្រូវការបានបំពេញ ។

ក្នុងករណីដែលមានការបញ្ចូលគ្នា ដើម្បីបង្កើតសហគមន៍ថ្មី នីតិវិធី និងរបៀបរបបក្នុងការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច ចំពោះសហគមន៍ថ្មីនេះ ត្រូវធ្វើតាមនីតិវិធីដែលមានចែងក្នុងមាត្រា៥ នៃព្រះរាជក្រឹត្យនេះ ។

ការទទួលស្គាល់អង្គភាពថ្មីមានអនុភាពដូចតទៅ :

- រាល់សហគមន៍ដែលត្រូវបានបញ្ចូលគ្នានោះត្រូវបានលុបឈ្មោះចេញពីបញ្ជី
- សហគមន៍ថ្មីទទួលយកបន្ត ទាំងទ្រព្យ ទាំងបំណុលរបស់សហគមន៍ ដែលត្រូវបានរំលាយបញ្ចូលគ្នា
- សមាជិកទាំងឡាយណា ដែលមិនបានសុំលាលែងនៅពេលមានការបញ្ចូលគ្នា ត្រូវនៅជាសមាជិករបស់សហគមន៍ថ្មី ។

ក្នុងករណីដែលមានការរំលាយបញ្ចូលគ្នាដោយស្រូបយក ឬ ដោយរួបរួមគ្នាបង្កើតសហគមន៍ថ្មី សហគមន៍ដែលត្រូវគេស្រូបយកនោះ ត្រូវបានលុបឈ្មោះចេញពីបញ្ជី ហើយសកម្មភាពព្រមទាំងបុគ្គលិកដែលមិនបានលាឈប់ ត្រូវបានសហគមន៍ដែលស្រូបយកនោះទទួលយកទាំងអស់ ។

វិធាន និង នីតិវិធីនៃការរំលាយបញ្ចូលគ្នា និង ការស្រូបយកសហគមន៍មួយផ្សេងទៀត ត្រូវកំណត់ក្នុងអនុក្រឹត្យមួយដោយឡែក ។

**មាត្រា ២៥ .-**

ផ្អែកទៅលើសេចក្តីសម្រេចរបស់មហាសន្និបាត សហគមន៍អាចបំបែកខ្លួនជាពីរ ឬ ច្រើនបាន ដែលមានលក្ខន្តិកៈដូចគ្នា ។ សេចក្តីសម្រេចនេះត្រូវមានគម្រោង បែងចែកទ្រព្យ និងបំណុល ព្រមទាំងបញ្ជីនៃសមាជិកសហគមន៍នីមួយៗ ដែលទើបនឹងបង្កើតថ្មី ។ ល។

ទោះបីជាមានការបែងចែកបំណុលក៏ដោយ ក៏សហគមន៍ដែលកើតមកពីការបំបែកខ្លួននេះ ត្រូវទទួលខុសត្រូវរៀង១ខ្លួនផង និងរួមគ្នាផង ចំពោះបំណុលរបស់សហគមន៍ ដែលបានបំបែកចេញ ។ ក្នុងកម្រិតព្រំដែននៃលក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ ដែលត្រូវបានបំបែក សមាជិករបស់សហគមន៍ថ្មី នៅតែទទួលខុសត្រូវចំពោះបំណុលរបស់សហគមន៍ ដែលត្រូវបានបំបែកនោះ ។

សហគមន៍នីមួយៗដែលទើបនឹងបង្កើតឡើង ត្រូវតែគោរពតាមនីតិវិធី និង របៀបរបបសុំការទទួលស្គាល់ និង ការចុះបញ្ជីដូចបានកំណត់រួចមកហើយ កំណត់ក្នុងមាត្រា៥នៃព្រះរាជក្រឹត្យនេះ។

**មាត្រា ២៦ .—**

មហាសន្និបាតត្រូវសម្រេចការរំលាយសហគមន៍ចោល បើមានមូលហេតុដូចតទៅ ៖—

- គ្មានសកម្មភាពក្នុងរយៈពេលពីរ ( ០២ ) ឆ្នាំជាប់ៗគ្នា
- ការធ្វើបានសម្រេច ឬ ការផុតរលត់ទៅនៃកម្មវត្ថុ
- បំណុលមានកម្រិតខ្ពស់ហួសហេតុ ច្រើនជាងពាក់កណ្ដាល ( ១/២ ) ដើមទុន
- ធនក្ស័យ ឬ អសោធនភាពជាប្រចាំ

ដោយមិនបង្អែបង្អង់ មហាសន្និបាតត្រូវជ្រើសតាំងអ្នកជម្រះបញ្ជីដែលមានសមត្ថកិច្ច និង មានសមត្ថភាពម្នាក់ ឬ ច្រើននាក់ជាសមាជិក ឬ មិនមែនជាសមាជិកសហគមន៍ ។

ក្នុងករណីដែលមហាសន្និបាតមិនព្រមសម្រេចរំលាយសហគមន៍ ទោះជាបានដឹងថាមានមូលហេតុដូចខាងលើកើតមានហើយក៏ដោយ ក៏តុលាការមានសមត្ថកិច្ចត្រូវសម្រេចរំលាយដោយស្វ័យប្រវត្តិ បើសិនជាមានការតវ៉ាណាមួយ ។ តុលាការតែងតាំងភ្លាមអ្នកជម្រះបញ្ជីម្នាក់ ( ០១ ) ឬ ច្រើននាក់ ជាសមាជិក ឬមិនមែនសមាជិកសហគមន៍។ សេចក្ដីសម្រេចពីការជម្រះបញ្ជីត្រូវតែផ្សព្វផ្សាយតាមរបៀបដូចការចុះបញ្ជីសហគមន៍ដែរ ។ តាមរយៈនេះ ម្ចាស់បំណុលទាំងឡាយ ត្រូវដាក់ពាក្យទាមទារ ឬ ធ្វើការជំទាស់ចំពោះ ការជម្រះបញ្ជីនោះទៅអ្នកទទួលបន្ទុក ជម្រះបញ្ជីក្នុងរយៈពេលពីរ ( ២ ) ខែ ចាប់ពីពេលបានផ្សព្វផ្សាយ ។

**មាត្រា ២៧ .—**

អ្នកជម្រះបញ្ជីត្រូវទទួលរ៉ាប់រងអំណាចទាំងអស់ពីក្រុមប្រឹក្សាភិបាល ពីគណៈកម្មាធិការត្រួតពិនិត្យ និង ពីនាយកគ្រប់គ្រង ចាប់ពីថ្ងៃតែងតាំងទៅ ហើយត្រូវយកអំណាចនេះទៅប្រើសម្រាប់តែជាកម្មវត្ថុនៃការជម្រះបញ្ជីប៉ុណ្ណោះ ។

មុននឹងចាប់ដំណើរការជម្រះបញ្ជី អ្នកជម្រះបញ្ជីត្រូវធ្វើតារាងតុល្យការ ហើយបញ្ជូនទៅតុលាការមានសមត្ថកិច្ច។ បន្ទាប់ពីបិទការជម្រះបញ្ជីសហគមន៍ត្រូវបានលុបឈ្មោះចេញពីបញ្ជី ។ ការលុបឈ្មោះពីបញ្ជីត្រូវផ្សព្វផ្សាយតាមរបៀបដូចការចុះបញ្ជីដែរ ។ តាមរយៈនេះ ម្ចាស់បំណុលដែលបានប្រកាសអំពីបំណុលរបស់ខ្លួនឱ្យគេដឹងឮ ត្រូវតវ៉ាក្នុងរយៈពេលប្រាំមួយ ( ០៦ ) ខែ បន្ទាប់ពីការចុះផ្សាយតាមតារាងបែងចែកសំណង ដែលកំណត់ឡើងដោយអ្នកជម្រះបញ្ជី ។

ផុតរយៈពេលនេះ ការរលត់នៃបំណុលទាំងឡាយ ត្រូវចាត់ចែងសងតាមអាទិភាពដូចតទៅ ៖—/.

- សោហ៊ុយសម្រាប់ការជម្រះបញ្ជី
- បំណុលនិងប្រាក់បៀវត្សបុគ្គលិកបម្រើការងារក្នុងសហគមន៍ និងពន្ធអាករដែលត្រូវបង់ជូនរដ្ឋ
- បំណុលដែលបានតវ៉ាទាមទារក្នុងកាលបរិច្ឆេទកំណត់តាមសិទ្ធិបុរិមា
- សំណងភាគហ៊ុនតាមតម្លៃជម្រះបញ្ជី

បើសិនជាក្រោយពីការបែងចែកនេះរួច ហើយអ្នកជម្រះបញ្ជីកត់សម្គាល់ថាមាននៅសល់ទ្រព្យទៀត អ្នកជម្រះបញ្ជីត្រូវប្រគល់ទ្រព្យនេះទៅឱ្យសហគមន៍ណាមួយផ្សេងទៀត ឬ ឱ្យទៅអង្គការណាមួយ ដែលបម្រើផលប្រយោជន៍រួម ។ បើសិនជាក្រោយពីការជម្រះបញ្ជីទៅ ឃើញថាមានឱនភាព សមាជិកត្រូវទទួលខុសត្រូវរៀងៗខ្លួនផង និង រួមគ្នាផងចំពោះឱនភាពក្នុងកម្រិតដែលបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ ។ នៅពេលបញ្ចប់អាណត្តិ អ្នកជម្រះបញ្ជីត្រូវបញ្ជូនរបាយការណ៍ សកម្មភាព និងតារាងតុល្យការបិទសកម្មភាព ជូនតុលាការមានសមត្ថកិច្ច បើមានសំណូមពរពីតុលាការនេះ ។

**មាត្រា ២៨ .–**

ក្រៅពីសិទ្ធិរបស់ជនគ្រប់រូបប្តឹងទៅតុលាការ វិវាទទាំងឡាយដែលកើតចេញពីការអនុវត្តព្រះរាជក្រឹត្យនេះ រវាងសមាជិក និងសមាជិកសហគមន៍ក្តី រវាងសមាជិកនិងសហគមន៍ក្តី រវាងអង្គភាពផ្ទៃក្នុងនៃសហគមន៍ក្តី ឬ រវាងអង្គភាពក្រៅណាមួយ និងសហគមន៍ក្តី គ្រប់វិវាទទាំងអស់នោះ ត្រូវដាក់ក្រោមមជ្ឈត្តីវិនិច្ឆ័យរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលត្រូវតែងតាំងគណៈកម្មាធិការមួយ ដែលមានតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទម្នាក់ តំណាងអាជ្ញាធរឃុំ-សង្កាត់ម្នាក់ ព្រមទាំងបុគ្គលដែលមិនពាក់ព័ន្ធនឹងវិវាទនេះមួយចំនួន ដែលគេយល់ថាអាចនឹងជួយជ្រោមជ្រែងក្នុងការដោះស្រាយវិវាទនេះ ។

## ជំពូកទី៣
## សហភាពសហគមន៍កសិកម្ម

**មាត្រា ២៩ .–**

សហគមន៍កសិកម្មចាប់ពីពីរ ( ០២ )ឡើងទៅ អាចចងជាមួយគ្នា បង្កើតជាសហភាពសហគមន៍បាន ។ ឈ្មោះរបស់សហគមន៍ដែលទើប នឹងកើតពីចំណងថ្មីនេះ ត្រូវបញ្ជាក់ដោយពាក្យសហភាពសហគមន៍កសិកម្មជាកំហិត ។

**មាត្រា ៣០ .–**

សកម្មភាពដែលសហភាពសហគមន៍បំពេញបន្ថែមលើសកម្មភាពសហគមន៍ ដែលជាសមាជិកមានជាអាទិ៍គឺ :

- ផ្តល់ជំនួយចាំបាច់ទាំងឡាយ ក្នុងការដឹកនាំ និង ការគ្រប់គ្រងនៃសហគមន៍សមាជិក
- បង្កើត និង គ្រប់គ្រងមូលនិធិមួយសម្រាប់ផ្តល់ហិរញ្ញវត្ថុដល់សវនកម្ម ឬ ការត្រួតពិនិត្យមកពីក្រៅចំពោះសហគមន៍សមាជិក មូលនិធិនេះបានមកពីវិភាគទានចាំបាច់របស់សហគមន៍សមាជិក ទៅតាមសមាមាត្រនៃភាគហ៊ុន ដែលត្រូវបានចុះឈ្មោះជាស្រេចហើយ ។ល។

- បង្កើត និងគ្រប់គ្រងមូលនិធិធានាមួយសម្រាប់សម្រួលការខ្ចីបុលរបស់សហគមន៍សមាជិក
- ផ្តល់ពត៌មានទាំងឡាយដែលអាចធ្វើឱ្យមានការរីកចំរើន ដល់សកម្មភាពរបស់សមាគមសហគមន៍
- ការខិតខំគាំទ្រក្នុងការបណ្តុះបណ្តាលជានិរន្តរ ដល់សមាជិកសហគមន៍
- វិភាគតម្រូវការរបស់សមាជិក និងការពារផលប្រយោជន៍របស់សមាជិក ចំពោះមុខអាជ្ញាធរសាធារណៈ និងដៃគូរឯកជន
- ជួយសម្រុះសម្រួលឱ្យបានល្អការវិវាទ ដែលកើតមានរវាងសមាជិក និងតតិយជន
- ចូលរួមក្នុងការផ្សព្វផ្សាយ ពន្យល់ច្បាប់ និងបទប្បញ្ញត្តិទាក់ទងនឹងសហគមន៍ ។

## ជំពូកទី៤
## បុរេសហគមន៍
### ផ្នែកទី១
### និយមន័យ និងការរៀបចំបង្កើត

**មាត្រា ៣១ .-**

បុរេសហគមន៍កសិកម្មជានីតិបុគ្គលឯកជន ដែលបង្កើតឡើង និងគ្រប់គ្រងដោយស្វ័យតពីសំណាក់រូបវន្តបុគ្គល ដែលប្រមូលផ្តុំគ្នាដោយចេតនា និងដោយគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន ក្នុងន័យបង្កើតផលិតភាពរបស់ខ្លួន និងរួមចំណែកក្នុងការលើកដំកើងសេដ្ឋកិច្ច និងសង្គមកិច្ច ។ សមាជិកនៃបុរេសហគមន៍ត្រូវរួមចំណែកក្នុងដើមទុន ព្រមទាំងសុខចិត្តទទួលគ្រោះបង់ខាត និងភាគផលតាមសមាមាត្រភាគទុនដែលបានចូលរួម ។

**មាត្រា ៣២ .-**

ដើម្បីបង្កើតបុរេសហគមន៍កសិកម្ម ត្រូវមានរូបវន្តបុគ្គលយ៉ាងតិចម្ភៃប្រាំ ( ២៥ ) នាក់ ។ អាចចូលជាសមាជិកបុរេសហគមន៍កសិកម្មបានរាល់នីតិបុគ្គល ដែលមានមុខរបរចម្បងស្ថិតនៅក្នុងវិស័យកសិកម្ម ។ ដើម្បីនឹងកកើតទទួលបុគ្គលិកលក្ខណៈគតិយុត្តិជាបុរេសហគមន៍កសិកម្ម ត្រូវមានការរៀបចំ និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ហើយត្រូវចុះឈ្មោះក្នុងបញ្ជីនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-ក្រុង ។ ក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ គិតចាប់ពីថ្ងៃប្រជុំសន្និបាតកំណើតដំបូង ប្រធានបុរេសហគមន៍កសិកម្ម ត្រូវដាក់ពាក្យសុំការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច ដោយភ្ជាប់ជាមួយ នូវឯកសារចាំបាច់អនុលោមតាមមាត្រា ៣៣ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣៣ .-**

ពាក្យសុំចុះបញ្ជីត្រូវមានភ្ជាប់ជាមួយនូវឯកសារដូចតទៅ :

- បទបញ្ជាផ្ទៃក្នុងរបស់បុរេសហគមន៍កសិកម្ម ដែលមានចុះកាលបរិច្ឆេទ និងហត្ថលេខា ឬស្នាមមេដៃរបស់សមាជិកអ្នក៨ៗ.

ផ្តើមបង្កើតទាំងអស់ចំនួន ពីរច្បាប់

- កំណត់ហេតុសន្និបាតកំណើតដំបូងមានហត្ថលេខា ឬ ស្នាមមេដៃរបស់សមាជិកអ្នកផ្តើមបង្កើតចំនួន មួយច្បាប់
- បញ្ជីឈ្មោះសមាជិកគណៈនាយកដែលមានបញ្ជាក់ឈ្មោះ អាសយដ្ឋាន និង មុខងារ មួយច្បាប់
- សំណាកហត្ថលេខា ឬ ស្នាមមេដៃអ្នកដែលមានសិទ្ធិតំណាងបុរេសហគមន៍កសិកម្ម មួយច្បាប់
- ភស្តុតាងនៃភាគទុនដែលបានផ្ញើមកហើយ យ៉ាងតិចចំនួនពាក់កណ្តាលនៃភាគទុនសរុប ដែលត្រូវបានបង់រួចហើយ ព្រមទាំងថេរវេលាអតិបរមាដើម្បីបង់ប្រាក់នៅសល់ ដែលមិនត្រូវឱ្យលើសពី មួយ(១)ឆ្នាំ ។

**មាត្រា ៣៤ .—**

ក្រោយដែលបានទទួលឯកសារសម្រាប់ការបង្កើតស្របទៅនឹងមាត្រា ៣៣ រួចហើយ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត-ក្រុង ត្រូវចេញលិខិតទទួលការដាក់ពាក្យសុំ ដែលមានចុះកាលបរិច្ឆេទ និងហត្ថលេខា ។

បុរេសហគមន៍កសិកម្ម ត្រូវទទួលលេខចុះបញ្ជីពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-ក្រុង ក្នុងរយៈពេលមិនហួសពីដប់ប្រាំ ( ១៥ ) ថ្ងៃ ។ លេខនេះត្រូវតែចុះនៅលើគ្រប់ឯកសារទាំងឡាយ ដែលបុរេសហគមន៍កសិកម្មធ្វើទំនាក់ទំនងជំនួញជាមួយតតិយជន ។

បើសិនជាឯកសារមានការខ្វះខាត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-ក្រុង ត្រូវជូនដំណឹងទៅបុរេសហគមន៍កសិកម្ម ក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ ចាប់ពីថ្ងៃដាក់ពាក្យសុំទៅ ដោយបញ្ជាក់ពីវិធានការកែតម្រូវដែលត្រូវធ្វើ ។

**មាត្រា ៣៥ .—**

បទបញ្ជាផ្ទៃក្នុងរបស់បុរេសហគមន៍កសិកម្មគឺជាលក្ខន្តិកៈ ។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវបានអនុម័តដោយមហាសន្និបាត ។

បទបញ្ជាផ្ទៃក្នុងត្រូវបញ្ជាក់ពីនិទ្ទេសដូចតទៅ :

- ឈ្មោះបុរេសហគមន៍កសិកម្ម
- ទីស្នាក់ការ និងអាសយដ្ឋាន
- កម្មវត្ថុ
- ភាគទុននីមួយៗមានតម្លៃស្មើគ្នា
- ភាតព្វកិច្ច និងសិទ្ធិរបស់សមាជិក
- ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់សមាជិក ចំពោះបំណុលរបស់បុរេសហគមន៍កសិកម្មរបស់ខ្លួន
- លក្ខណវិនិច្ឆ័យ និងល័ក្ខខ័ណ្ឌការលាឈប់ និងការបណ្តេញចេញនៃសមាជិក
- ល័ក្ខខ័ណ្ឌនៃការកោះប្រជុំមហាសន្និបាត និងគណៈនាយក
- សមាសភាពគណៈនាយក
- ល័ក្ខខ័ណ្ឌនៃការរំសាយខ្លួនដោយស្ម័គ្រចិត្ត
- នីតិវិធីមជ្ឈត្តិវិនិច្ឆ័យរវាងសមាជិក និងបុរេសហគមន៍កសិកម្ម ល.ល.

- របៀបរបបនៃការកាន់សៀវភៅបញ្ជី
- ការត្រួតពិនិត្យពីខាងក្រៅ
- កាតព្វកិច្ចរបស់សមាជិក
- កម្រិតព្រំដែនសិទ្ធិរបស់សមាជិក
- សិទ្ធិរបស់សមាជិក
- ការសុំចូលការព្យួរ និងការបណ្តេញចេញនៃសមាជិក

បទបញ្ជាផ្ទៃក្នុងគំរូរបស់បុរេសហគមន៍កសិកម្ម ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ផ្នែកទី២

## កាតព្វកិច្ចរបស់បុរេសហគមន៍កសិកម្ម

**មាត្រា ៣៦ .-**

បុរេសហគមន៍កសិកម្ម ត្រូវរក្សាទុកនៅទីស្នាក់ការរបស់ខ្លួននូវបទបញ្ជាផ្ទៃក្នុង ដែលមានការបញ្ជាក់ត្រឹមត្រូវ ហើយនៅជាធរមានមួយ ( ០១ ) ច្បាប់និងត្រូវកាន់សៀវភៅបញ្ជីឈ្មោះសមាជិក និងភាគទុនរបស់គេ សៀវភៅកំណត់ហេតុទាំងឡាយនៃកិច្ចប្រជុំមហាសន្និបាត ព្រមទាំងសៀវភៅបញ្ជីផ្សេងៗទៀត ដែលបានគ្រោងទុកជាមុននៅក្នុងបទបញ្ជាផ្ទៃក្នុង ។

សៀវភៅបញ្ជីទាំងនេះឱ្យសមាជិក ឬ អ្នកត្រួតពិនិត្យជាផ្លូវការ អាចរកពតិមានមើលនៅពេលណាក៏បាន ។

**មាត្រា ៣៧ .-**

បុរេសហគមន៍កសិកម្ម ត្រូវស្ថិតនៅក្រោមច្បាប់ជាធរមាន ស្តីពីការត្រួតពិនិត្យពីខាងក្រៅចំពោះគណនីនានា និងការគ្រប់គ្រង ។

## ផ្នែកទី៣

## កាតព្វកិច្ច និងសិទ្ធិរបស់សមាជិក

**មាត្រា ៣៨ .-**

សមាជិកម្នាក់ៗត្រូវតែគោរពបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចរបស់មហាសន្និបាត ។ សមាជិកម្នាក់ៗត្រូវបង់ភាគទុន ដែលបានចុះឈ្មោះទិញដោយអនុលោមទៅតាមល័ក្ខខ័ណ្ឌ ដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង ។ ក្នុងកម្រិតព្រំដែននៃបទបញ្ជាផ្ទៃក្នុង សមាជិកម្នាក់ៗត្រូវទទួលខុសត្រូវរួម ចំពោះបំណុលរបស់បុរេសហគមន៍កសិកម្មរបស់ខ្លួន ។ ការទទួលខុសត្រូវរបស់បុរេសហគមន៍កសិកម្មនេះ មានសុពលភាពរហូតដល់ទៅពីរ ( ០២ ) ឆ្នាំ ក្រោយពីការលាលែងរបស់សមាជិកចំពោះបំណុលដែលបុរេសហគមន៍ បានខ្ចីមុនពេលដែលសមាជិកសាមីបានលាលែង ។៚

**មាត្រា ៣៩ .–**

សមាជិកណាដែលពុំបានបង់ប្រាក់សម្រាប់ភាគទុនរបស់ខ្លួន ពុំបានបង់ប្រាក់ផ្សេងទៀត ដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង ឬ ពុំបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួន ចំពោះបុរេសហគមន៍កសិកម្ម ពុំអាចចូលរួមក្នុងសេចក្តីសម្រេចរបស់បុរេសហគមន៍ ឬ ទាញយកចំណេញពីបុរេសហគមន៍ ឬ ក៏កាន់តំណែងក្នុងអង្គភាពផ្ទៃក្នុងណាមួយបានឡើយ ។

**មាត្រា ៤០ .–**

អនុលោមតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ សមាជិកណាដែលគោរពបទបញ្ជាផ្ទៃក្នុងរបស់បុរេសហគមន៍ ត្រូវមានសិទ្ធិ :

- ចូលរួមប្រជុំមហាសន្និបាតនានា ហើយមានសិទ្ធិបោះឆ្នោតស្មើភាពគ្នា ជាមួយនឹងសមាជិកផ្សេងទៀត
- បោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត ជាសមាជិកគណៈនាយករបស់បុរេសហគមន៍កសិកម្ម
- ទទួលពត៌មានពីសមាជិកគណៈនាយក ពីសភាពការណ៍សេដ្ឋកិច្ចនៃបុរេសហគមន៍កសិកម្ម
- កោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីដោះស្រាយបញ្ហាណាមួយ បើមានមួយភាគបី ( ១/៣ ) នៃសមាជិករបស់បុរេសហគមន៍យ៉ាងតិចដែលបានស្នើសុំ
- ស្នើសុំការត្រួតពិនិត្យមកពីក្រៅនៃសេវាពាណិជ្ជកម្មទទួលបន្ទុកខាងកសិកម្ម បើមានពីរភាគបី ( ២/៣ ) នៃសមាជិកទាំងអស់ដែលបានស្នើសុំ
- ស្នើសុំបញ្ចូលក្នុងរបៀបវារៈមហាសន្និបាតនូវបញ្ហាទាំងឡាយ ដែលទាក់ទងនឹងការគ្រប់គ្រងរបស់បុរេសហគមន៍
- ទទួលប្រាក់ចំណេញតាមចំណែករបស់ខ្លួន
- ជួលសេវារបស់បុរេសហគមន៍កសិកម្មស្មើភាពគ្នា ជាមួយសមាជិកផ្សេងទៀត
- ទទួលភាគទុនដែលបង់ហើយ បូកនឹងការប្រាក់ស្របតាមបទបញ្ជាផ្ទៃក្នុង ឬប្រាក់ដែលត្រូវបង្វិលមកវិញក្នុងករណីចាំបាច់ អាចចុះថយទៅតាមសមាមាត្រនៃឱនភាពដែលបានទទួល ។

**មាត្រា ៤១ .–**

ក្នុងកម្រិតព្រំដែននៃព្រះរាជក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុង បុគ្គលណាក៏អាចដាក់ពាក្យសុំចូលជាសមាជិកបុរេសហគមន៍បានតាមការពិនិត្យសម្រេចរបស់មហាសន្និបាត ។

អាចព្យួរ ឬបណ្តេញសមាជិកណាដែលធ្វើអ្វីប៉ះពាល់ខ្លាំង ដល់ផលប្រយោជន៍បុរេសហគមន៍កសិកម្ម ឬសមាជិករបស់បុរេសហគមន៍ ។ ការព្យួរ ឬការបណ្តេញចេញ ត្រូវប្រកាសដោយមហាសន្និបាត បន្ទាប់ពីបានទុកឱ្យសមាជិកសាមីមានលទ្ធភាពការពារខ្លួនរួចហើយ ។ រយៈពេលនៃការព្យួរមិនត្រូវឱ្យហួសពីមួយ ( ០១ ) ឆ្នាំទេ ។

## ផ្នែកទី៤

## ការប្រព្រឹត្តទៅ

**មាត្រា ៤២ .-**

សមាសភាពនៃសន្និបាតកំណើតដំបូង មានបណ្តាសមាជិកស្ថាបនិកនៃបុរេសហគមន៍ និងសមាជិកស្ម័គ្រចិត្តនានា ។សន្និបាតនេះរៀបចំឯកសារសម្រាប់ភ្ជាប់ទៅនឹងពាក្យសុំការទទួលស្គាល់ ហើយនឹងចេញសេចក្តីសម្រេចចាំបាច់សម្រាប់សកម្មភាពឆ្នាំទីមួយ ។

**មាត្រា ៤៣ .-**

មហាសន្និបាតសមាជិកជាអង្គការកំពូល និងខ្ពស់បំផុតសម្រាប់ពិភាក្សាអនុម័ត និងធ្វើសេចក្តីសម្រេចរបស់បុរេសហគមន៍កសិកម្ម ។ សមាជិកទាំងអស់ ត្រូវរួមប្រជុំជាមហាសន្និបាតសាមញ្ញ យ៉ាងតិចពីរដងក្នុងមួយឆ្នាំ ។

ពុំមានសមាជិកណាម្នាក់ មានសិទ្ធិកោះប្រជុំមហាសន្និបាតវិសាមញ្ញបានឡើយ លើកលែងតែប្រធាន ។ ក្នុងករណីមានសមាជិកចំនួនពីរភាគបី (២/៣) នៃសមាជិកទាំងអស់ ព្រមព្រៀងគ្នាស្នើឱ្យមានកិច្ចប្រជុំមហាសន្និបាតវិសាមញ្ញនេះ ប្រធានត្រូវតែកោះប្រជុំ ។

**មាត្រា ៤៤ .-**

មហាសន្និបាតមានភារកិច្ច :

- ឱ្យសច្ចានុម័តលើកំណត់ហេតុនៃកិច្ចប្រជុំកន្លងទៅ
- អនុម័ត ឬ កែសម្រួលបទបញ្ជាផ្ទៃក្នុង
- បោះឆ្នោតជ្រើសតាំងតាមរបៀបបោះឆ្នោតជាសម្ងាត់នូវប្រធាន និងសមាជិកដទៃទៀតនៃគណៈនាយក ក្នុងចំណោមសមាជិក និងដកហូតតំណែងពីអ្នកទាំងនោះវិញ ។
- កំណត់ភារកិច្ចរបស់គណៈនាយក
- កំណត់កម្រិតអតិបរមានៃការជំពាក់បំណុល និងអនុញ្ញាតឱ្យវិនិយោគ ឬ ចងការមូលនិធិ
- អនុញ្ញាតឱ្យសមាជិកខ្ចីប្រាក់
- កំណត់ការបែងចែកប្រាក់ចំណេញ និងការបង្វិលប្រាក់ឱ្យសមាជិកវិញ
- កំណត់របៀបបំពេញឱនភាពជាយថាហេតុ
- អនុម័តកម្មវិធីសកម្មភាព និងថវិកាសម្រាប់គណៈនាយកចំពោះការិយបរិច្ឆេទខាងមុខ
- សម្រេចឱ្យចូល ឲ្យរ និងបណ្តេញសមាជិកចេញ
- សម្រេចធ្វើបដិរូប ឬ រំលាយបុរេសហគមន៍កសិកម្ម ។ល។

**មាត្រា ៤៥ .–**

មហាសន្និបាតអាចពិភាក្សានិងសម្រេចបាន លុះត្រាតែមានវត្តមានមួយភាគបី ( ១/៣ ) នៃសមាជិក ដែលបានចុះឈ្មោះនៅថ្ងៃកោះប្រជុំ ។ មហាសន្និបាតត្រូវដឹកនាំដោយប្រធានគណៈនាយក ឬ ដោយប្រធានអង្គប្រជុំជ្រើសរើស ក្នុងចំណោមសមាជិកវត្តមាន ។ មហាសន្និបាតតែងតាំងលេខាធិការអង្គប្រជុំដែលធ្វើកំណត់ហេតុក្នុងនោះ មានសេចក្ដីសម្រេចដែលបានធ្វើនៅពេលប្រជុំព្រមទាំងបញ្ជី សមាជិកវត្តមាន ។ លេខាធិការ និងប្រធានអង្គប្រជុំ ត្រូវចុះហត្ថលេខាលើកំណត់ហេតុ ។ សមាជិកនីមួយៗមានសំឡេងតែមួយគត់ នៅក្នុងមហាសន្និបាត ហើយពុំអាចបញ្ជូនតំណាងមកជំនួសបានទេ ។

សេចក្ដីសម្រេចរបស់មហាសន្និបាតដែលទាក់ទង និងបទបញ្ជាផ្ទៃក្នុង ការធ្វើបដិរូប ឬការរំលាយបុរេសហគមន៍ ត្រូវឱ្យមានការយល់ព្រមពីពីរភាគបី ( ២/៣ ) នៃសមាជិកវត្តមាន ។ សេចក្ដីសម្រេចដទៃទៀត តម្រូវឱ្យមានការយល់ព្រមពីមតិភាគច្រើននៃសមាជិកវត្តមាន ។

**មាត្រា ៤៦ .–**

គណៈនាយករបស់បុរេសហគមន៍កសិកម្ម មានសមាសភាពយ៉ាងតិចបី ( ០៣ ) នាក់ ។ ឪពុកម្ដាយ បងប្អូនបង្កើត ប្ដីប្រពន្ធ ពុំអាចធ្វើជាសមាជិកនៅក្នុងគណៈនាយកបានទេ ។ អាណត្តិរបស់សមាជិកគណៈនាយកមានរយៈពេលបី ( ០៣ ) ឆ្នាំ ។ ប្រធានជាអ្នកដឹកនាំ អង្គប្រជុំមហាសន្និបាត និងគណៈនាយក ហើយជាតំណាងរបស់បុរេសហគមន៍ ក្នុងទំនាក់ទំនងផ្សេងៗជាមួយតតិយជន ។

**មាត្រា ៤៧ .–**

ក្នុងកម្រិតព្រំដែននៃព្រះរាជក្រឹត្យនេះ បទបញ្ជាផ្ទៃក្នុង និងសេចក្ដីសម្រេចរបស់មហាសន្និបាត គណៈនាយកមានអំណាចយ៉ាងទូលាយលើការដឹកនាំ និងការគ្រប់គ្រងបុរេសហគមន៍ ។

ភារកិច្ចរបស់គណៈនាយកមានដូចតទៅ

- កាន់បញ្ជីគណនេយ្យសាមញ្ញរបស់បុរេសហគមន៍កសិកម្ម
- រៀបចំកិច្ចប្រជុំមហាសន្និបាតនានា
- ដាក់ជូនមហាសន្និបាតសាមញ្ញនូវរបាយការណ៍ស្ដីពីការគ្រប់គ្រងការិយបរិច្ឆេទកន្លងទៅ កម្មវិធីសកម្មភាព និងគម្រោងថវិកាសម្រាប់ការិយបរិច្ឆេទខាងមុខ
- រៀបចំកិច្ចប្រជុំមហាសន្និបាតវិសាមញ្ញ កាលណាការប្រព្រឹត្តទៅ របស់បុរេសហគមន៍កសិកម្មតម្រូវឱ្យមានការពិភាក្សា អនុម័ត ឬធ្វើសេចក្ដីសម្រេច ឬ តាមការស្នើសុំរបស់សមាជិកអនុលោមទៅតាមមាត្រា៤៣ នៃព្រះរាជក្រឹត្យនេះ ។ល។

**មាត្រា ៤៨ .—**

សមាជិកគណៈនាយកទទួលខុសត្រូវរៀងៗខ្លួនផង និងរួមគ្នាផង ចំពោះកំហុសដែលបានធ្វើក្នុងការបំពេញមុខងាររបស់ខ្លួន ដោយមិនទាន់គិតដល់ពីការទទួលខុសផ្នែកព្រហ្មទណ្ឌរបស់ខ្លួនឡើយ ។

## ផ្នែកទី៥
## បដិរូបកម្មទៅជាសហគមន៍

**មាត្រា ៤៩ .—**

បុរេសហគមន៍កសិកម្មជាសហគមន៍កសិកម្មបណ្តោះអាសន្ន ដែលមិនអាចមានអត្ថិភាពលើសពីបី ( ០៣ ) ឆ្នាំបាន ។ ពេលចប់រយៈពេលនេះ បុរេសហគមន៍កសិកម្មមានជម្រើសពីរយ៉ាង ឬ មួយក្លាយខ្លួនទៅជាសហគមន៍កសិកម្ម ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ ឬមួយរំសាយខ្លួន ។ ក្នុងករណីពិសេសបុរេសហគមន៍ អាចធ្វើពាក្យសុំទៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត-ក្រុងបាន ដោយបញ្ជាក់មូលហេតុសមរម្យ ដើម្បីសុំបន្តនៅជាបុរេសហគមន៍កសិកម្ម សម្រាប់រយៈពេលពីរ(០២ )ឆ្នាំតទៅ ទៀតក្នុងន័យថា ខ្លួននឹងបដិរូបជាសហគមន៍ កសិកម្មផ្អែកតាមក្នុងលក្ខណៈគាប់ប្រសើរក្នុងចន្លោះពេលនេះ ។

**មាត្រា ៥០ .—**

បុរេសហគមន៍កសិកម្មអាចប្តូរទៅជាសហគមន៍តែម្នាក់ឯង ឬ មួយចូលរួមជាមួយបុរេសហគមន៍ដទៃទៀតដែលមានបំណងដូចគ្នាបាន។ បដិរូបកម្មបុរេសហគមន៍កសិកម្ម ទៅជាសហគមន៍កសិកម្ម ត្រូវសម្រេចដោយមហាសន្និបាតវិសាមញ្ញ ។ មហាសន្និបាតនេះ នឹងក្លាយទៅជាសន្និបាតកំណើតដំបូងសហគមន៍ដែលត្រូវបង្កើត ។

ក្នុងករណីដែលមានបុរេសហគមន៍កសិកម្មច្រើនបញ្ចូលគ្នា ដើម្បីបង្កើតសហគមន៍ សន្និបាតកំណើតដំបូង ត្រូវមានសមាសភាពមកពីមហាសន្និបាត នៃក្រុមដែលបញ្ចូលគ្នា រួមគ្នាជាមហាសន្និបាតវិសាមញ្ញ ។

បទប្បញ្ញត្តិដែលទាក់ទងទៅនឹងសហគមន៍នៅក្នុងព្រះរាជក្រឹត្យនេះ មានវិសាលភាពក្នុងករណីមានបដិរូបកម្ម ។

## ជំពូកទី៥
## បទប្បញ្ញត្តិផ្សេងៗ

**មាត្រា ៥១ .—**

គ្រប់អង្គការកសិករទាំងអស់ ដែលបានបង្កើតរួចហើយមានរយៈពេលមួយ (១) ឆ្នាំ គិតចាប់ពីថ្ងៃចូលជាធរមាន នៃព្រះរាជក្រឹត្យនេះ ដើម្បីរៀបរៀងលក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ហើយអាចដាក់ពាក្យសុំការទទួលស្គាល់ជាសហគមន៍កសិកម្ម ឬ ចុះបញ្ជីជាបុរេសហគមន៍កសិកម្មបានអនុលោមទៅតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ ។ល។

មាត្រា ៥២ .–

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥៣ .–

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។៙.៖.

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០១

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខៈ ១៤៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ចាន់

# ព្រះរាជក្រឹត្យ

នស / រកត /០៧០១/២៣៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានបញ្ឈប់ភារកិច្ចរបស់ឯកឧត្តម សូ ម៉ារ៉ា ពីអគ្គនាយក នៃក្រសួងទេសចរណ៍ អោយមកបំរើការងារជាមន្ត្រីរាជការ នៅក្រោមឱវាទរបស់ក្រសួងទេសចរណ៍ ។

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ១៤៤ ច.ល

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០១

ចម្លងចេញពីច្បាប់ដើម សម្រាប់ចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស/រកត/០៧០១/២៣៦

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើត រាជបណ្ឌិតសភាកម្ពុជា
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១** : ត្រូវបានតែងតាំងមន្ត្រី ០២ រូប នៃរាជបណ្ឌិតសភាកម្ពុជា ដូចមានខាងក្រោម ÷

១- ឯកឧត្តមបណ្ឌិត **ឆយ យីហ៊ាង** ជាប្រធានវិទ្យាស្ថានវប្បធម៌ និង វិចិត្រសិល្បៈ នៃរាជបណ្ឌិតសភាកម្ពុជា ។

២- លោកបណ្ឌិត **ជា លោង** ជាអគ្គលេខាធិការរង នៃរាជបណ្ឌិតសភាកម្ពុជា មានឋានៈស្មើ អគ្គនាយក ។

**មាត្រា២** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ: ១៤៧ ច.ល

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible]

# ព្រះរាជក្រឹត្យ

នស / រកត /០៧០១/២៣៧

ស្តីពី

**ការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង**
**របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ /០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០១៩៩ / ២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

**មាត្រា ១ :** ត្រូវបានកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន និងអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ សំដៅបង្កើនប្រសិទ្ធភាពក្នុងការដឹកនាំបញ្ជាកងយោធពលខេមរភូមិន្ទ ។

**មាត្រា ២ :** ក្រោមព្រះមហាក្សត្រ ដែលជាមេបញ្ជាការកំពូល នៃកងយោធពលខេមរភូមិន្ទ អគ្គមេបញ្ជាការ គឺជាអ្នកដែលមានសមត្ថកិច្ចក្នុងការបញ្ជាកងយោធពលខេមរភូមិន្ទទាំងមូល និងជាអ្នកទទួលខុសត្រូវចាត់តាំង។ល។

អនុវត្តភារកិច្ចការពារជាតិរបស់រាជរដ្ឋាភិបាល សំដៅរក្សាអោយបាននូវឯករាជ្យ អធិបតេយ្យភាព សន្តិភាព ស្ថេរភាព សេរីភាព លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងបូរណភាពដែនដីទាំងមូល នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣ :** រចនាសម្ព័ន្ធចាត់តាំង តួនាទី ភារកិច្ចរបស់អគ្គសេនាធិការ និងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ ដែលមានកន្លងមក ត្រូវបានកែសម្រួលដោយរួមបញ្ចូលគ្នា បង្កើតជាអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទតែមួយ ដឹកនាំគ្រប់គ្រង និងបញ្ជាដោយអគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ដែលអមដោយអគ្គមេបញ្ជាការរង ដោយមាននាយសេនាធិការចំរុះ និងនាយរងសេនាធិការចំរុះមួយចំនួនធ្វើជាសេនាធិការ មានរចនាសម្ព័ន្ធចាត់តាំងដូចខាងក្រោម :

ក- អគ្គបញ្ជាការដ្ឋានរួមមាន :

- ខុទ្ទកាល័យ
- អធិការដ្ឋាន
- នាយកដ្ឋានស្រាវជ្រាវការកិច្ច
- មជ្ឈមណ្ឌលស្រាវជ្រាវយុទ្ធសាស្ត្រយោធា
- ទីចាត់ការបុគ្គលិក
- ទីចាត់ការកលយុទ្ធ
- ទីចាត់ការចលនូបត្ថម្ភ
- ទីចាត់ការឃោសនា និងពត៌មាន
- ទីចាត់ការហិរញ្ញ

ព្រមទាំងបណ្តាបញ្ជាការដ្ឋានទ័ពជំនាញ បណ្តាទីចាត់ការ បណ្តាសាលា និងកងឯកភាពអន្តរាគមន៍មួយចំនួនទៀត ។

ខ- បញ្ជាការដ្ឋានកងទ័ពជើងគោក

គ- បញ្ជាការដ្ឋានកងទ័ពជើងទឹក

ឃ- បញ្ជាការដ្ឋានកងទ័ពជើងអាកាស

ក្រៅពីនេះ អគ្គមេបញ្ជាការអាចមានទីប្រឹក្សាមួយចំនួនទៀត ដើម្បីជាជំនួយការងារ ។

**មាត្រា ៤ :** មេបញ្ជាការកងទ័ពជើងគោក មេបញ្ជាការកងទ័ពជើងទឹក មេបញ្ជាការកងទ័ពជើងអាកាស ដែលមានមេបញ្ជាការរងមួយចំនួនជាជំនួយការ ជាអ្នកទទួលខុសត្រូវចំពោះមុខ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ក្នុងការដឹកនាំ គ្រប់គ្រង និងបញ្ជាកងទ័ពតាមប្រភេទទ័ពរៀងៗខ្លួន ។

**មាត្រា ៥ :** ប្រគល់ជូនអគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ នូវតួនាទីក្នុងការកំណត់រចនាសម្ព័ន្ធចាត់តាំង និងភារកិច្ចលំអិតជាក់ស្តែងនៃអគ្គបញ្ជាការដ្ឋាន និងបញ្ជាការដ្ឋាន នៃប្រភេទទ័ពនីមួយៗ ព្រមទាំងតួនាទីក្នុងការរៀបចំស្នើតែងតាំង និងដំឡើងឋានន្តរសក្តិនាយទាហាន តាមស្ថាប័ននានា ចំណុះអគ្គបញ្ជាការដ្ឋាន ដូចមានចែងក្នុងមាត្រា ៣ ខាងលើ ។៚

**មាត្រា ៦** : សមត្ថកិច្ចក្នុងការតែងតាំង និងផ្លាស់ប្តូរមុខតំណែងនាយទាហានចំណុះអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ត្រូវបានកំណត់ដូចខាងក្រោម :

ក- អគ្គមេបញ្ជាការ អគ្គមេបញ្ជាការរង នាយសេនាធិការចំរុះ មេបញ្ជាការកងទ័ពជើងគោក ត្រូវបានតែងតាំង និងផ្លាស់ប្តូរមុខតំណែង ដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។

ខ- នាយរងសេនាធិការចំរុះ មេបញ្ជាការរងកងទ័ពជើងគោក មេបញ្ជាការ មេបញ្ជាការរងកងទ័ពជើងទឹក មេបញ្ជាការ មេបញ្ជាការរងកងទ័ពជើងអាកាស មេបញ្ជាការ មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស មេបញ្ជាការ មេបញ្ជាការរងយោធភូមិភាគ ទីប្រឹក្សាអគ្គមេបញ្ជាការ នាយកនាយកដ្ឋាន នាយកទីចាត់ការ នាយករងទីចាត់ការ នាយ នាយរងស្ថាប័ន និងមុខតំណែងដទៃទៀតនៅតាមស្ថាប័ន និងកងឯកភាពចំណុះអគ្គបញ្ជាការដ្ឋាន ដែលមានឋានន្តរស័ក្តិ ចាប់ពីថ្នាក់វរសេនីយ៍ឯកឡើងទៅ ត្រូវបានតែងតាំង និងផ្លាស់ប្តូរមុខតំណែងដោយអនុក្រឹត្យ ។

គ- ក្រៅពីមុខតំណែងដែលបានរៀបរាប់ក្នុងចំណុច ក និង ខ ចំពោះនាយទាហានដែលមានឋានន្តរស័ក្តិចាប់ពីថ្នាក់វរសេនីយ៍ទោចុះក្រោម ត្រូវបានតែងតាំង និងផ្លាស់ប្តូរមុខតំណែងដោយសេចក្តីសំរេចរបស់អគ្គមេបញ្ជាការ តាមសំណើរបស់មេបញ្ជាការប្រភេទទ័ពនីមួយៗ ប្រធានស្ថាប័ន និងកងឯកភាពចំណុះអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ៧** : ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៩ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៨** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ និងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៩** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕ល.ត.

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១*

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ១៤៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] ឥសាន**

# ព្រះរាជក្រឹត្យ

នស / រកត /០៧០១/២៣៨

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម ស្វស ស្វ័មេត ប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ជាឯកអគ្គរាជទូត ប្រធានស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំការិយាល័យអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា នៅទីក្រុងហ្សឺណែវ នៃប្រទេសស្វីស ។

**មាត្រា ២** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខៈ ១៤៧ ច.ល

ដើម្បីចម្លងចែកជូន

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible] តាន

*រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១*

# ព្រះរាជក្រឹត្យ

នស/រកត/០៧០១/២៣៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២១១/០៣ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១ : តែងតាំងឯកឧត្តម យ៉ាវ ប៊ុនម៉េង ជាសមាជិកទី១ នៃអាជ្ញាធរអគ្គិសនីកម្ពុជា មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ៦៤៩ ច.ល

ដើម្បីចម្លងចែក

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០១

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៦ អនក្រ.បក

៙៙៙*៙៙៙

***អនុក្រឹត្យ***

***ស្តីពីការផ្ទេរឥណទានថវិកា***

************

***រាជរដ្ឋាភិបាល***

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកាចំណាយ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ៥.០០០ លានរៀល ( ប្រាំពាន់លានរៀល ) ពីជំពូក ៤០ (ចំណាយផ្សេងៗ )នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការផ្គូសផុលតូច ) របស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់រៀបចំការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ________

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :..៦៧..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រើប្រាស់គណនី
## ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

៣☆៤

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ២០០១
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីបែបបទ នៃ ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពី ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១** : អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើប្រាស់គណនី " ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ " ដែលត្រូវបានបង្កើតឡើង តាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ លើមុខសញ្ញាចំណាយសំរាប់ បើកផ្តល់ប្រាក់ឧបត្ថម្ភគោលនយោបាយជូនមន្ត្រីរាជការ នៅក្រុមហ៊ុនដឹកជញ្ជូនដោយរថយន្ត នៃ ក្រសួងសាធារណការ និង ដឹកជញ្ជូន ចំនួន ៩៥៧ នាក់ ដែលមានទឹកប្រាក់សរុបចំនួន USD 645.300,0 ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន និង ប្រធានស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី 17 ខែ 7 ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ២
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៨៦ ...អនក្រ.ចក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

* * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

### សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី SUWANNA GAUNTLETT តំណាងអង្គការជំនួយសត្វព្រៃដែលបានឧបត្ថម្ភថវិកាចំនួន ២៤៩.២៣៨ដុល្លាអាមេរិក ជួយថែរក្សាសត្វព្រៃអោយមានការរីកចំរើនទៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានសទ្ធផលល្អៗ

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

<u>កន្លែងទទួលៈ</u>

- ក្រសួង ព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និងមាត្រា២
- រាជកិច្ច - កាលប្បវត្តិ - ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៦៨៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២. នស ; ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម / ០១៩៦ / ០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា១** : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **ចាន់ កុសល** អនុប្រធាននាយកដ្ឋានពត៌មានទូទៅ នៃ ក្រសួងមហាផ្ទៃ ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០១*

**ហ៊ុន សែន**

*__កន្លែងទទួល:__*
*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ២*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៤៩៨ អនក្រ.តត**

# អនុក្រឹត្យ

## ស្តីពី

## ការដកហូតមុខតំណែង និងតែងតាំង ឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ . នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម / ០១៩៦ / ០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យ នស/ រកត/ ០៦០១/ ១៩៤ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការដកហូតឋានន្តរស័ក្តិ នាយនគរបាលជាតិ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១** : ត្រូវបានដកហូតមុខតំណែងលោក **រស់ សារី** ពីប្រធាននាយកដ្ឋានសុខាភិបាល នៃក្រសួងមហាផ្ទៃ អោយទៅជា មន្ត្រី នគរបាលជាតិ ។

**មាត្រា២** : ត្រូវបានតែងតាំងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោក **រស់ សារី** មន្ត្រីនគរបាលជាតិ- នៃ ក្រសួងមហាផ្ទៃ ។

**មាត្រា៣** : រាល់ការកំណត់ទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០១*

**ហ៊ុន សែន**

*កន្លែងទទួល:*

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ៤*
*-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៩៩ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ . នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម / ០១៩៦ / ០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា១** : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរៈសេនីយ៍ឯក** ជូនលោកវរៈសេនីយ៍ទោ **សួស សុខុន** អនុប្រធានអធិការដ្ឋានកិច្ចការនគរបាល នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និង នគរបាល នៃក្រសួងមហាផ្ទៃ ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល:*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ...៣០០...អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់លោកអគ្គនាយកក្រុមហ៊ុន អេស.ធី.ភី អ៊ិនធើណេស្យូណល ( ខេមបូឌា ) ជាប្អិក

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **តែ ឡោខចិ** អគ្គនាយកក្រុមហ៊ុនអេស.ធី.ភី អ៊ិនធើណេស្យូណល ( ខេមបូឌា ) ជាប្អិក ដែលបានចំណាយធនធានផ្ទាល់ខ្លួនយ៉ាងច្រើនសន្ធឹកសន្ធាប់ ដើម្បីស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធ រួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិលើគ្រប់វិស័យ ចាប់តាំងពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០១ សរុបទឹកប្រាក់ចំនួន ១៩២.៦០០ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង លោកអគ្គនាយកក្រុមហ៊ុនអេស.ធី.ភី អ៊ិនធើណេស្យូណល ( ខេមបូឌា ) ជាប្អិក ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧០១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ស្ពឺ

### សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ខូច តៀវស៊ាង** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនយ៉ាងច្រើន ដើម្បីចូលរួមកសាងផ្លូវគ្រួសក្រហមមួយខ្សែ មានប្រវែង ២២ គីឡូម៉ែត្រ និង ទទឹង ០៨ ម៉ែត្រ ដាក់លូទឹកចំនួន ៦០ កន្លែង ស្ពានខ្លាតខ្លីចំនួន ០៣ កន្លែង ឆ្លងកាត់ពីរឃុំគឺ ឃុំក្រាំងដីវ៉ាយ និង ឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ មានតំលៃជាទឹកប្រាក់សរុបចំនួន ១៤៩.០០០ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៣០២ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

•••••••

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានកិត្តិយសសមាគមន៍មិត្តភាព អាស៊ី ខ្មែរ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនតំណាងរាជរដ្ឋាភិបាល និងប្រជាជនជប៉ុន ០១ រូប និង សមាគមន៍ ០២ ដែលបានជួយសាងសង់អាគារសិក្សា ០២ ខ្នង មាន ១០ បន្ទប់ នៅសាលាបឋម សិក្សាថ្មផុស ឃុំជីខ្មារ ស្រុកទ្រាំង និងសាលាបឋមសិក្សា ដោម ឃុំតាអូ ស្រុកគីរីវង់ ខេត្តតាកែវ ព្រមទាំងផ្តល់ទឹកស្អាតឥណទានជនបទ ចំណាយអស់ទឹកប្រាក់សរុបចំនួន ៤៧.៨៦៦ ដុល្លារ អាមេរិក ដូចមានរាយនាមខាងក្រោមនេះ÷

១-ឯកឧត្តម GOTARO OGAWA ឯកអគ្គរាជទូតជប៉ុន ជាតំណាងរាជរដ្ឋាភិបាល និងប្រជាជនជប៉ុន

២-សមាគមន៍មិត្តភាព អាស៊ី ខ្មែរ (KAFS)

៣-សមាគមន៍មិត្តភាព អាស៊ី ជប៉ុន (JAFS-MORIGUCHI)

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានកិត្តិយសសមាគមន៍មិត្តភាព អាស៊ី ខ្មែរ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និងមាត្រា ២
-រាជកិច្ច
-កាលប្បវត្តិ-ឯកសារ.

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣០៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ ជូនលោកស្រី Geneviève JAVALOYES នាយិកានៃទីភ្នាក់ងារបារាំង សំរាប់អភិវឌ្ឍន៍ ( AFD ) ដែលមានគុណបំណាច់ និង ស្នាដៃល្អ ក្នុងការបំពេញបេសកកម្ម ស្វែងរកការគាំទ្រផ្តល់ជំនួយពីសំណាក់រដ្ឋាភិបាលបារាំង ដើម្បីស្តារ និង កសាងប្រទេសកម្ពុជា ប្រកបដោយជោគជ័យ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

[illegible] សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៣០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការប្រគល់មេដាយសហមេត្រី

* * * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ សេនា ជូនលោកស្រី ហ្សឺណេវីយ៉ែវ ហ្សាវ៉ាឡូយេស Geneviève JAVALOYES និង លោក ហ្វីលីព ឌីរៃរិច Philippe DIERICKX ជាទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់ជំនួយជាច្រើនសំរាប់គាំទ្រលើ ៣ គំរោងក្នុងកម្មវិធីរបស់ក្រសួងអភិវឌ្ឍន៍ជនបទ គិតជាទឹកប្រាក់សរុបចំនួន ១២,៩ លាន FRF និង ៨.៥ លាន EURO ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ កក្កដា ឆ្នាំ ២០០១
**នាយករដ្ឋមន្ត្រី**
**ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដកហូតឋានន្តរសក្តិ និងបណ្តេញចេញពីក្របខ័ណ្ឌនគរបាលជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ បង្កើតក្រសួងមហាផ្ទៃ
- ដោយពិនិត្យឃើញភាពមិនប្រក្រតី ក្នុងការបំពេញភារកិច្ចរបស់លោក ស្រេង ស្រ៊ាង
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១** : ត្រូវបានដកហូតឋានន្តរសក្តិ ថ្នាក់វរសេនីយ៍ឯក និងបញ្ឈប់ភារកិច្ចលោក ស្រេង ស្រ៊ាង និងបណ្តេញចេញពីក្របខ័ណ្ឌនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គនាយកនគរបាលជាតិ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០១*

សែន

__ចម្លងជូន :__

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៣២ អនក្រ.បក.

# អនុក្រឹត្យ

## ស្តីពីការបញ្ចប់ភារកិច្ចរបស់មន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ / អនក្រ . បក / ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ របស់ក្រសួងទេសចរណ៍
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**មាត្រា ១** : ត្រូវបានបញ្ចប់ភារកិច្ចឯកឧត្តម សូ ម៉ារ៉ា ពីអគ្គលេខាធិការអាជ្ញាធរជាតិទេសចរណ៍កម្ពុជា ពីសមាជិកក្រុមប្រឹក្សាភិបាលអាជ្ញាធរអប្សរា និងពីប្រធានគណៈកម្មការសិក្សាស្រាវជ្រាវអំពីគំរោងគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រាសាទព្រះវិហារ ។

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០១

សែន

<u>ចម្លងជូន</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៨៣...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ម៉ម ម៉ារ៉ាឌី** ជាប្រធាននាយកដ្ឋានផែនការទូទៅនៃក្រសួងផែនការ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ឱ្យបានសំរេច ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១
**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**
ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ដូចមាត្រា ២
-កាលប្បវត្តិ ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ៣០៤ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ បង្កើតក្រសួងមហាផ្ទៃ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងលោក សំកុល សុខន ជាប្រធាននាយកដ្ឋានពន្ធនាគារ ចំណុះអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ៨៣.០៨...អនក្រ-តត**

# អនុក្រឹត្យ

## ស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

......

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤/ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤/ ចុះថ្ងៃទី២៦ ខែតុលាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០១

## សម្រេច

**មាត្រា១.-**

ត្រូវបានដាក់ឱ្យចូលនិវត្តន៍ លោក ងាន ខាត បច្ចុប្បន្នជាប្រធានសហគ្រាសសំណង់ភ្នំពេញ

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យបានសម្រេចចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ដូចមាត្រា ២ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៣១០ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

✧✧✧✧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០២គ្រឿង ជូនតំណាងសហគមន៍អឺរ៉ុប ផ្នែកគំរោងជំនួយ EU / ASAC ចំនួនពីររូប ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលបានខិតខំសហការយ៉ាងជិតស្និទ្ធជាមួយ កងយោធពលខេមរភូមិន្ទ លើគំរោងដកហូតអាវុធ និងបណ្តុះបណ្តាលព្រមទាំងផ្តល់ សៀវភៅ សំភារៈ បរិក្ខារ សាងសង់ និងជួសជុលឃ្លាំង ដើម្បីស្តុកទុកអាវុធគ្រាប់ជាតិផ្ទុះ ដែលមានតំលៃជាទឹកប្រាក់សរុបចំនួន ៣០០.០០០ USD ដូចមានរាយនាមខាងក្រោមនេះ ÷

១-ឧត្តមសេនីយ៍ត្រី H.J. VAN.DER GRAAF

២-វរសេនីយ៍ទោ ALAIN.PERI GAUD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធផលចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧១១...អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតម្លើងឋានន្តរសក្តិជាកិច្ចបច្ឆាមរណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត / ០៧០១ / ២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ វរសេនីយ៍ឯក ជាកិច្ចបច្ឆាមរណៈ ជូនចំពោះសព÷

- វរសេនីយ៍ទោ ហែម វ៉ន អត្តលេខ ០០២៦៥៣ មេបញ្ជាការរង កងរាជអាវុធហត្ថ ខេត្តកណ្តាល
- វរសេនីយ៍ទោ ពិន ចាន់រ៉ុង អត្តលេខ ០០៣៤៣៣ នាយរងការិយាល័យអភិវឌ្ឍន៍បញ្ជាការដ្ឋាន កងទ័ពជើងគោក
- វរសេនីយ៍ទោ អ៊ួន ម៉ៅ អត្តលេខ ០០០៩៨៥ នាយការិយាល័យយោធាតំបន់ យោធភូមិភាគទី ៤

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ- កាលប្បវត្តិ ✓

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣១២ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំង និងផ្លាស់ប្តូរមុខតំណែងនាយទាហាន

៣៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត / ០៧០១ / ២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំង និងផ្លាស់ប្តូរមុខតំណែងឧត្តមសេនីយ៍ត្រី ព្រុំ ជីវិណា អត្តលេខ ០០៤៤២៧ ជាមេការងារខុទ្ទកាល័យ នៃអគ្គបញ្ជាការដ្ឋាន បច្ចុប្បន្ន ជាមេបញ្ជាការរងវិស្វកម្មរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣១៣.អនក្រ.តត

# អនុក្រឹត្យ

## ស្ដីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ / នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកត / ១១៩៦ / ០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងមន្ត្រីរាជការ ដូចមានរាយនាមខាងក្រោម :

១- លោក អ៊ិច សារូ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

២- លោក រលេង ខី ជាប្រធាន នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ

៣- លោក ឡាយ ខោហារិទ្ធ ជាប្រធាន នាយកដ្ឋានកិច្ចការនយោបាយ ក្រសួងមហាផ្ទៃ

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**ចម្លងជូន** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៨១...សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការ ដើម្បីស្រាវជ្រាវវត្ថុបុរាណ ដែលបានកប់ទុកក្នុងបរិវេណសារមន្ទីរវប្បធម៌ ខេត្តបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ពិនិត្យសំណូមពរចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការ ដើម្បីស្រាវជ្រាវវត្ថុបុរាណដែលបានកប់ទុកក្នុងបរិវេណសារមន្ទីរវប្បធម៌ ខេត្តបាត់ដំបង តាំងពីឆ្នាំ ១៩៧០ រួមមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- សម្តេចព្រះរាម | **នរោត្តម បុប្ផាទេវី** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ព្រះប្រធាន |
| ២- ឯកឧត្តម | **ខិម យ៉ិនទៀង** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៣- ឯកឧត្តម | **សេង លីមនៅ** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- ឯកឧត្តម | **ហោ ឡុត** | សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក |
| ៥- ឯកឧត្តម | **ឃឹម សារិទ្ធ** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | សមាជិក |

៦- លោក អ៊ុន ១ន ប្រធាននាយកដ្ឋានបិតិកភ័ណ្ឌវប្បធម៌ សមាជិក

៧- លោក ប៊ុន សុវត្ថិ មន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

៨- លោក OLIVIER de BERNON សមាជិកសាលាបារាំងចុងបូព៌ា ទីប្រឹក្សា

**ប្រការ ២ :** គណៈកម្មការស្រាវជ្រាវវត្ថុបុរាណ ដែលបានកប់ទុកក្នុងបរិវេណសារមន្ទីរវប្បធម៌ខេត្តបាត់ដំបង មានភារកិច្ច ដូចតទៅ :

-ធ្វើការទំនាក់ទំនង និងសហការជាមួយរដ្ឋអំណាចខេត្ត ដើម្បីរក្សាសុវត្ថិភាពក្នុងការជីកយកវត្ថុបុរាណ និងការដឹកជញ្ជូន

-ធ្វើការស្រាវជ្រាវជីកយកវត្ថុបុរាណ ចុះក្នុងបញ្ជីសារពើភ័ណ្ឌ ដោយដាក់លេខកូដ និងថតរូបផ្សព្វផ្សាយ ដើម្បីជៀសវាងការជួញដូរវត្ថុបុរាណទាំងនោះ ។

-ធ្វើការទំនាក់ទំនងជាមួយអ្នកជំនាញការសាលាបារាំងចុងបូព៌ា ដើម្បីកំណត់ពីអាយុកាល និងប្រភពនៃវត្ថុបុរាណទាំងនោះ ។

**ប្រការ ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៤៩៨ សហវ.ពន

# ប្រកាស

ស្តីពី

## ការកំណត់មូលដ្ឋានគិតអាករលើតម្លៃបន្ថែម លើការដឹកជញ្ជូនទំនិញឬអ្នកដំណើរ

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០១
- បានឃើញប្រកាស ស្តីពីការអនុវត្តន៍អាករលើតម្លៃបន្ថែម លើការដឹកជញ្ជូនទំនិញ ឬ អ្នកដំណើរ លេខ៣២៦ សហវ.ពជ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០១
- បានឃើញការចាំបាច់របស់នាយកដ្ឋានពន្ធដារ

## សម្រេច :

**ប្រការ ១.-** អនុវត្តតាមមាត្រា៦១ មាត្រា៦៣ មាត្រា៦៤ នៃច្បាប់ស្តីពីសារពើពន្ធ មាត្រា៩៤ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម និងប្រការ១ នៃប្រកាសលេខ ៣២៦ សហវ.ពជ អាករលើតម្លៃបន្ថែមលើការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរ ត្រូវបានអនុវត្តដូចតទៅ :

១- សហគ្រាសដែលធ្វើការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរ ចូលមកក្នុង ឬទៅក្រៅទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើការបែងចែកផលរបរបានមកពីការដឹកជញ្ជូនអន្តរជាតិ និងការដឹកជញ្ជូនក្នុងស្រុក ដើម្បីជាមូលដ្ឋានក្នុងការគិតប្រាក់អាករ ដូចខាងក្រោមនេះ :

ក- តម្លៃនៃការដឹកជញ្ជូនពីកន្លែងមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា មកកន្លែងមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា(កំពង់ផែអន្តរជាតិ ព្រលានយន្តហោះអន្តរជាតិ ឬច្រកចូលដំបូងមកក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា) ត្រូវគិតអាករតាមអត្រាសូន្យភាគរយ ។

ខ- តម្លៃដឹកជញ្ជូនពី កំពង់ផែអន្តរជាតិ ព្រលានយន្តហោះអន្តរជាតិ ឬច្រកចូលដំបូងមកក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា មកកន្លែងណាមួយទៀតក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា រួមនិងកម្រៃសេវាដទៃទៀតដែលជាអាទិ៍មាន សេវាលើកដាក់ទំនិញ សេវារត់បែបបទគយ សេវាវេចខ្ចប់ ឬសេវាដទៃផ្សេងទៀត ត្រូវគិតប្រាក់អាករតាមអត្រា ១០ ភាគរយ ។

គ- ប្រាក់ពន្ធគយនិងអាករនានានៅពេលនាំចូល ប្រាក់បង់ថ្លៃត្រួតពិនិត្យទំនិញ (CAMCONTROL FEE) និងកម្រៃវាយតម្លៃទំនិញ (SGS FEE) ដែលសហគ្រាសដឹកជញ្ជូនបង់ជួសមុខឱ្យសហគ្រាសម្ចាស់ទំនិញ មិនត្រូវគិតប្រាក់អាករទេ ។

២- ក្នុងករណីដែលសហគ្រាសដឹកជញ្ជូន ទទួលរត់បែបបទនានានៅពេលនាំចូលជំនួសមុខឱ្យសហគ្រាសម្ចាស់ទំនិញនោះ ស្ថាប័នឬសហគ្រាសនានា ដែលធ្វើសេវា ត្រួតពិនិត្យ លើកដាក់ទំនិញ ឬសេវាដទៃផ្សេងទៀត ត្រូវចេញវិក្ក័យបត្រអាករឱ្យទៅសហគ្រាសដឹកជញ្ជូន ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ត្រឹមត្រូវនូវ ឈ្មោះ អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្មអតប របស់សហគ្រាសដឹកជញ្ជូននោះ ។ ប៉ុន្តែប្រសិនបើសហគ្រាសម្ចាស់ទំនិញរត់បែបបទនានាដើម្បីនាំទំនិញចេញឬចូលដោយខ្លួនឯងនោះ ស្ថាប័ន ឬសហគ្រាសនានា ដែលធ្វើសេវា ត្រួតពិនិត្យ លើកដាក់ទំនិញ ឬសេវាដទៃផ្សេងទៀត ត្រូវចេញវិក្ក័យបត្រអាករឱ្យទៅសហគ្រាសម្ចាស់ទំនិញ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ត្រឹមត្រូវនូវ ឈ្មោះ អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្មអតប របស់សហគ្រាសម្ចាស់ទំនិញនោះ ។

៣- សហគ្រាសដឹកជញ្ជូន ត្រូវចេញវិក្ក័យប័ត្រឱ្យទៅសហគ្រាសម្ចាស់ទំនិញ ដោយត្រូវបែងចែកតម្លៃនៃការដឹកជញ្ជូនអន្តរជាតិ តម្លៃនៃការដឹកជញ្ជូនក្នុងស្រុករួមទាំងសេវាផ្សេងទៀត និងប្រាក់ពន្ធគយនិងអាករនានា ប្រាក់បង់ថ្លៃត្រួតពិនិត្យនិងកម្រៃវាយតម្លៃទំនិញ ដែលសហគ្រាសដឹកជញ្ជូនបង់ជួសសហគ្រាសម្ចាស់ទំនិញ ដូចមានចែងក្នុងកថាខ័ណ្ឌ១ នៃប្រការនេះ ។ ការសសេរវិក្ក័យប័ត្រ ត្រូវអនុវត្តតាមគំរូក្នុងឧបសម្ព័ន្ធទី១ ភ្ជាប់ជាមួយប្រកាសនេះ ។

៤- សហគ្រាសត្រូវបានអនុញ្ញាតិនូវឥណទានអាករលើធាតុចូល ចំពោះតែវិក្កយបត្រអាករដែលមានបញ្ជាក់ឈ្មោះ អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្មអតប របស់សហគ្រាសនោះតែប៉ុណ្ណោះ ។

៥- សហគ្រាសដែលធ្វើសេវាបញ្ជូនទំនិញចូលមកក្នុង ឬចេញទៅក្រៅព្រះរាជាណាចក្រកម្ពុជា តាមរយៈសហគ្រាសដឹកជញ្ជូនដទៃទៀត ឬធ្វើអាជីវកម្មទិញ-លក់សំបុត្រដឹកជញ្ជូនអន្តរជាតិ ត្រូវអនុវត្តដូចគ្នាទៅនឹងសហគ្រាសដឹកជញ្ជូនដែរ ដោយត្រូវកត់ត្រារួមគ្នាលើវិក្កយបត្រតែមួយនូវតម្លៃដែលត្រូវទូទាត់យកពីអតិថិជនដូចខាងក្រោមនេះ :

ក- តម្លៃនៃការដឹកជញ្ជូនអន្តរជាតិដែលក្រុមហ៊ុនដឹកជញ្ជូនគិតយកពីសហគ្រាស ត្រូវគិតអាករតាមអត្រាសូន្យភាគរយ ។

ខ- តម្លៃនៃសេវាដទៃទៀតដែលជាអាទិ៍មាន សេវាព្រលាន សេវាដឹកជញ្ជូនក្នុងស្រុក សេវាវេចខ្ចប់ សេវារត់បែបបទបញ្ជូនទំនិញចេញចូល សេវាកម្រៃជើងសារជាដើម ត្រូវគិតអាករតាមអត្រា ១០% ។

ការសសេរវិក្ក័យប័ត្រ ត្រូវអនុវត្តតាមគំរូក្នុងឧបសម្ព័ន្ធទី២ ភ្ជាប់ជាមួយប្រកាសនេះ ។

៦- សហគ្រាសជាភ្នាក់ងារលក់សំបុត្រដឹកជញ្ជូន ហើយទទួលកម្រៃពីការលក់សំបុត្រទាំងនោះតាមអត្រាណាមួយនៃថ្លៃសំបុត្រ ត្រូវគិតប្រាក់អាករតាមអត្រា ១០% លើប្រាក់កម្រៃដែលត្រូវទទួលពីសហគ្រាសដើមនោះ បង់ជូននាយកដ្ឋានពន្ធដារ ។ សហគ្រាសដើមអាចយកវិក្កយបត្រអាករដែលសហគ្រាសជាទីភ្នាក់ងារចេញឱ្យទៅស្នើសុំឥណទានអាករលើធាតុចូល សម្រាប់កាត់កងនឹងអាករលើធាតុចេញ ។ ការគណនាប្រាក់អាករសម្រាប់សហគ្រាសជាភ្នាក់ងារ និងសហគ្រាសដើម មានឧទាហរណ៍បញ្ជាក់ក្នុងឧបសម្ព័ន្ធទី៣ ភ្ជាប់ជាមួយប្រកាសនេះ ។

៧- សម្រាប់គោលដៅនៃប្រកាសនេះ ពាក្យ "ការផ្តល់ផ្គង់សេវាដែលទាក់ទិននឹងការដឹកជញ្ជូនអ្នកដំណើរ និងទំនិញជាអន្តរជាតិ" ដែលចែងក្នុងវាក្យខ័ណ្ឌ ឃ នៃកថាខ័ណ្ឌ ២ នៃមាត្រា ៥៤ នៃអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម សំដៅដល់ សេវានានាដែលព្រលានយន្តហោះឬកំពង់ផែ ផ្តល់ផ្គង់ឱ្យដល់មធ្យោបាយដឹកជញ្ជូនដែលរួមមាន សេវានាំផ្លូវ ចុះចតឬចូលចត ឬសេវាផ្តល់ព័ត៌មានផ្សេងៗ ទាក់ទិននឹងការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរអន្តរជាតិ ។

៨- ដូចមានចែងក្នុងមាត្រា ៦១ នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងករណីដែលការបែងចែកតម្លៃនៃការផ្តល់ផ្គង់ដូចមានចែងក្នុង កថាខ័ណ្ឌ ១ កថាខ័ណ្ឌ ៥ និងកថាខ័ណ្ឌ ៦ នៃប្រការនេះ មិនតំណាងឱ្យតម្លៃពិតទេនោះ នាយកដ្ឋានពន្ធដារអាចកំណត់ចេញនូវតម្លៃមួយសម្រាប់ការផ្តល់ផ្គង់ ហើយតម្លៃនោះត្រូវបានចាត់ទុកថាជាតម្លៃត្រឹមត្រូវរហូតដល់ពេលសហគ្រាសមានឯកសារបញ្ជាក់ផ្សេងៗ ដែលនាយកដ្ឋានពន្ធដារយល់ព្រមផង ។

**ប្រការ ២.-** អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ នាយកខុទ្ទកាល័យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋានដែលពាក់ព័ន្ធ គ្រប់ស្ថាប័ននិងសហគ្រាសដែលទាក់ទិននឹងសកម្មភាពដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០០១

**គាត ឈន់**

**ចម្លងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន
- គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ ។

## ឧបសម្ព័ន្ធ ១

សហគ្រាស (ក). ទទួលដឹកទំនិញពីប្រទេស (ខ) មកក្រុងព្រះសីហនុតាមនាវា និងបន្តដោយរថយន្តមករាជធានីភ្នំពេញ ។ សហគ្រាសត្រូវកត់ត្រារួមគ្នាលើវិក្កយបត្រតែមួយ នូវតម្លៃដែលត្រូវទូទាត់យកពីសគ្រាស (គ) ជាម្ចាស់ទំនិញ ដោយធ្វើការបែងចែកដូចខាងក្រោមនេះ :

សហគ្រាសដឹកជញ្ជូន ក លេខអតប : VT 01. 1043333
អាសយដ្ឋាន លេខ ....
មហាវិថីព្រះមុនីវង្ស

អតិថិជន : សហគ្រាស គ
លេខអតប : VT 01. 1067777
អាសយដ្ឋាន លេខ ... មហាវិថីព្រះសីហនុ

| លរ. | បរិយាយ | តម្លៃ | អត្រាអាករ | ប្រាក់អាករ | តម្លៃរួមបញ្ចូលទាំងអាករ |
|---|---|---|---|---|---|
| 1 | ដឹកជញ្ជូនតាមសមុទ្រ | 800 | 0% | 0 | 800 |
| 2 | សេវាវេចខ្ចប់ | 100 | 10% | 10 | 110 |
| 3 | សេវាលើកដាក់ទំនិញ ( LOLO ) | 40 | 10% | 4 | 44 |
| 4 | សេវាកំប៉ៃបបខគយ | 200 | 10% | 20 | 220 |
| 5 | ដឹកជញ្ជូនក្នុងស្រុក | 300 | 10% | 30 | 330 |
| 6 | សេវាផ្សេងៗ | 50 | 10% | 5 | 55 |
| 7 | តម្លៃត្រួតពិនិត្យតម្លៃទំនិញ ( SGS ) | 80 | | | 80 |
| 8 | វិញ្ញាបនប័ត្រពិនិត្យទំនិញ ( CAMCONTROL) | 20 | | | 20 |
| 9 | ពន្ធគយ និងអាករនានា | 400 | | | 400 |
| | | | | | |
| | | | | | |
| | សរុប | 1,990 | | 69 | 2,059 |

ឬ

| លរ. | បរិយាយ | តម្លៃ |
|---|---|---|
| 1 | តម្លៃត្រួតពិនិត្យតម្លៃទំនិញ ( SGS ) | 80 |
| 2 | វិញ្ញាបនប័ត្រពិនិត្យទំនិញ ( CAMCONTROL) ) | 20 |
| 3 | ពន្ធគយ និងអាករនានា | 400 |
| | | 500 |
| 4 | ដឹកជញ្ជូនតាមសមុទ្រ | 800 |
| | | 800 |
| 5 | សេវាវេចខ្ចប់ | 100 |
| 6 | សេវាលើកដាក់ទំនិញ ( LOLO ) | 40 |
| 7 | សេវាកំប៉ៃបបខគយ | 200 |
| 8 | ដឹកជញ្ជូនក្នុងស្រុក | 300 |
| 9 | សេវាផ្សេងៗ | 50 |
| | | 690 |
| | | |
| | | VAT 10% 69 |
| | | 759 |
| | សរុបរួម | 2,059 |

## ឧបសម្ព័ន្ធ ២

សហគ្រាស (ក) ធ្វើសេវាបញ្ជូនទំនិញទៅក្រៅប្រទេសឱ្យរោងចក្រកាត់ដេរ (ខ) ។ សហគ្រាស (ក) ត្រូវចេញវិក្កយបត្រ តាមគំរូដូចខាងក្រោមនេះ :

**សហគ្រាស ក** លេខអតប : VT 01. 1045555
អាសយដ្ឋាន លេខ ....
មហាវិថីព្រះមុនីវង្ស

អតិថិជន : រោងចក្រកាត់ដេរ ខ
លេខអតប : VT 01. 1062222
អាសយដ្ឋាន លេខ ...... ផ្លូវលេខ ៦ A

| លរ. | បរិយាយ | តម្លៃ | អត្រាអាករ | ប្រាក់អាករ | តម្លៃរួមបញ្ចូលទាំងអាករ |
|---|---|---|---|---|---|
| 1 | ថ្លៃដឹកជញ្ជូន តាមអាកាស( Airwaybill Fees) | 130 | 0% | 0 | 130 |
| 2 | សេវាព្រលាន ( Terminal Charge ) | 50 | 10% | 5 | 55 |
| 3 | សេវាកាត់បែបបទ | 30 | 10% | 3 | 33 |
| 4 | សេវាវេចខ្ចប់ | 20 | 10% | 2 | 22 |
| 5 | ថ្លៃដឹកជញ្ជូនក្នុងស្រុក | 20 | 10% | 2 | 22 |
| | | | | | |
| | | | | | |
| | សរុប | **250** | | **12** | **262** |

ឬ

| លរ. | បរិយាយ | តម្លៃ |
|---|---|---|
| 1 | ថ្លៃដឹកជញ្ជូន តាមអាកាស( Airwaybill Fees) | 130 |
| | | **130** |
| 2 | សេវាព្រលាន ( Terminal Charge ) | 50 |
| 3 | សេវាកាត់បែបបទ | 30 |
| 4 | សេវាវេចខ្ចប់ | 20 |
| 5 | ថ្លៃដឹកជញ្ជូនក្នុងស្រុក | 20 |
| | | **120** |
| | | VAT 10% 12 |
| | | **132** |
| | សរុបរួម | **262** |

សហគ្រាស (ក) ទិញសំបុត្រយន្តហោះអន្តរជាតិពីក្រុមហ៊ុនដឹកជញ្ជូន ថ្លៃ ១៣០ ហើយលក់ចេញទៅវិញក្នុងតម្លៃ ១៤០ ។ សហគ្រាស (ក) ត្រូវ ចេញវិក្កយបត្រ តាមគំរូដូចខាងក្រោមនេះ :

**សហគ្រាស ក** លេខអតប : VT 01. 1044567
អាសយដ្ឋាន លេខ ......
អតិថិជន : លោក ម៉ៅ ម៉ុក មហាវិថីព្រះមុនីវង្ស

| លរ. | បរិយាយ | តម្លៃ | អត្រាអាករ | ប្រាក់អាករ | តម្លៃរួមបញ្ចូលទាំងអាករ |
|---|---|---|---|---|---|
| 1 | ថ្លៃដឹកជញ្ជូន ភ្នំពេញ-បាងកក (Airway Bill) | 130 | 0% | 0 | 130 |
| 2 | កម្រៃពីការទិញលក់ ( gain ) | 10 | 10% | 1 | 11 |
| | | | | | |
| | | | | | |
| | សរុប | **140** | | **1** | **141** |

ឬ

| លរ. | បរិយាយ | តម្លៃ |
|---|---|---|
| 1 | ថ្លៃដឹកជញ្ជូន ភ្នំពេញ-បាងកក (Airway Bill) | 130 |
| | | **130** |
| 2 | កម្រៃពីការទិញលក់ ( gain ) | 10 |
| | | VAT 10% 1 |
| | | 11 |
| | សរុបរួម | **141** |

## ឧបសម្ព័ន្ធ ៣

ក្រុមហ៊ុន (ក) ប្រើប្រាស់ទីភ្នាក់ងារ (ខ) ឱ្យលក់សំបុត្រដឹកជញ្ជូនឱ្យ ហើយផ្តល់កម្រៃ ២០% ដល់ទីភ្នាក់ងារ (ខ) ។ ក្នុងខែ ទីភ្នាក់ងារ (ខ) លក់បាន :

- សំបុត្រដឹកជញ្ជូនអន្តរជាតិចំនួន ៥០ សន្លឹក x ១៤០ (តម្លៃរួមបញ្ចូលទាំងអាករ 0%) = ៧.០០០
- សំបុត្រដឹកជញ្ជូនក្នុងស្រុកចំនួន ២០០ សន្លឹក x ៩០ (តម្លៃរួមបញ្ចូលទាំងអាករ ១០%) = ១៨.០០០

នាដំណាច់ខែ ទីភ្នាក់ងារ (ខ) ត្រូវគិតប្រាក់កម្រៃ = (៧.០០០ + ១៨.០០០) x ២០% = ៥.០០០ ។ ទីភ្នាក់ងារ (ខ) ត្រូវចេញវិក្កយបត្រឱ្យក្រុមហ៊ុន (ក) នូវទឹកប្រាក់ ៥.០០០ + ប្រាក់អាករ ៥០០ = ៥.៥០០ ហើយប្រគល់ប្រាក់ចំនួន ២៥.០០០ – ៥.៥០០ = ១៩.៥០០ ទៅឱ្យក្រុមហ៊ុនដឹកជញ្ជូន (ក) ។

ទីភ្នាក់ងារ (ខ) ត្រូវដាក់លិខិតប្រកាសអតប ដូចខាងក្រោមនេះ :

- អាករលើធាតុចូល = 0 (សន្មតថាគ្មាន)
- អាករលើធាតុចេញ = ៥០០ (គិតយកពីក្រុមហ៊ុន (ក) )
- អាករត្រូវបង់ = ៥០០

ក្រុមហ៊ុន (ក) ត្រូវដាក់លិខិតប្រកាសអតប ដូចខាងក្រោមនេះ :

- អាករលើធាតុចូល = ៥០០ (បង់ឱ្យទៅទីភ្នាក់ងារ (ខ) )
- អាករលើធាតុចេញ = ១.៦៣៦ (ក្នុងទឹកប្រាក់ ៧.០០០ ថ្លៃដឹកជញ្ជូនអន្តរជាតិ មានប្រាក់អាករ 0 និងទឹកប្រាក់ ១៨.០០០ ថ្លៃដឹកជញ្ជូនក្នុងស្រុក មានបង្កប់ប្រាក់អាករចំនួន ១៨.០០០ / ១១ = ១.៦៣៦)
- អាករត្រូវបង់ = ១.១៣៦ ។

៚៙៛៚

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
№ ៤៥៨ ឧរម៉ ឧតសល-ប្រក

រាជធានី-ភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៣៣៨ ឧក.ប្រក ចុះថ្ងៃទី ០៧-៤-៩៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញពាក្យស្នើសុំ បន្តដំណើរការសហគ្រាសចុងតូចកាត់ដេរសំលៀកបំពាក់ របស់លោក ស៊ុខ គន់ ចុះថ្ងៃទី ២៥-៦-០១ ។

# សំរេច

**ប្រការ១:-** អនុញ្ញាតអោយលោក ស៊ុខ គន់ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ២០៦២៦៨ ភ.ព ចុះថ្ងៃទី២២-៣-៩៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៤៨០៤-៦ ផ្លូវលេខ១២៨ សង្កាត់មិត្តភាព ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ បន្តដំណើរការ សហគ្រាសចុងតូចកាត់ដេរសំលៀកបំពាក់ នៅក្នុងទីតាំង ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

**ប្រការ២:-** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ៣:-** អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង លោក ស៊ុខ គន់ ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ៤:-** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចំលងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុង ភ្នំពេញ
- ខ័ណ្ឌ ឫស្សីកែវ

"ដើម្បីជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

[illegible signature]
ស៊ុយ ស៊ែម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

N° ៤៧៣ ឧស ថ ឧតស-ប្រក

រាជធានី-ភ្នំពេញ ថ្ងៃទី...១៩......ខែ.កក្កដា...ឆ្នាំ ២០០១

## ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ : នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បើកដំណើរការសិប្បកម្មកែឆ្នៃប្រេងរំអិល របស់លោក ង៉ែត ឌឿន ចុះថ្ងៃទី ០៨-៦-០១ ។
- បានឃើញការយល់ព្រមលេខ ១២៥៤ ក.ច ចុះថ្ងៃទី ១៥-៦-០១ របស់អភិបាលខេត្ត កំពង់ចាម ។

## សំរេច

**ប្រការ១:-** អនុញ្ញាតអោយលោក ង៉ែត ឌឿន ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ១៦២២៣៦ក.ច ចុះថ្ងៃទី២៩-០២-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិក្រែក ឃុំក្រែក ស្រុកពញាក្រែក ខេត្តកំពង់ចាម បើកដំណើរការសិប្បកម្មកែឆ្នៃប្រេងរំអិល នៅក្នុងទីតាំង ដីឡូត៍លេខDx0134 ផ្លូវជាតិលេខ៧ ភូមិសូងលិច ឃុំសូងលិច ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

**ប្រការ២:-** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ៣:-** អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកំពង់ចាម និង លោក ង៉ែត ឌឿន ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ៤:-** ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ស៊ុយ សែម

ចំលងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្ត កំពង់ចាម
- សាលាស្រុក ត្បូងឃ្មុំ

"ដើម្បីជ្រាប"

- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation - Religion - King

ទីស្តីការ
ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
Ministry of Posts and Telecommunications

រាជធានី. ភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០១

លេខ : ១៧៧ បទ.ប្រក

# ប្រកាស
## ស្តីពីការ តែងតាំង មន្ត្រីរាជការ
## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ,
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ,
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ,
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ,
- បានឃើញព្រះរាជក្រមលេខ សន/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ,
- បានឃើញអនុក្រឹត្យលេខ ៦៦អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ,
- យោងសារាចរណែនាំលេខ ១០.សរណន ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីនិតិវិធី នៃការតែងតាំងមន្ត្រីរាជការស៊ី វិល របស់រាជរដ្ឋាភិបាល ,
- យោងកំណត់ហេតុ ស្មារតីអង្គប្រជុំរបស់ថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១ ស្តីការតែងតាំងមន្ត្រីរាជការ ស៊ីវិល របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ,
- យោងចំណារឯកភាពរបស់ឯកឧត្តម អភិបាលខេត្តកោះកុង ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ,
- បានឃើញលិខិតលេខ ២១១ មស.តត ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០១ របស់រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ,
- បានឃើញការងារចាំបាច់របស់ក្រសួង ,

## សំរេច

**ប្រការ១ :** តែងតាំងលោក **ឆូច ឧុត្ដិ** ជាអនុប្រធានមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្តកោះកុង ។

<u>ប្រការ២</u> : មន្ត្រីរាជការ ដូចមានចែងក្នុងប្រការ ១ ខាងលើត្រូវអនុវត្តតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួន។

<u>ប្រការ៣</u> : ខុទ្ទកាល័យ, អធិការដ្ឋាន, គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង, គ្រប់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ ខេត្ត-ក្រុង និង សាមីខ្លួនត្រូវអនុវត្ត តាមខ្លឹមសារ នៃប្រកាសនេះ ។

<u>ប្រការ៤</u> : រាល់ប្រកាសទាំងឡាយណា ដែលផ្ទុយពីខ្លឹមសារ នៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

<u>ប្រការ៥</u> : ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

<u>កន្លែងទទួល</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ
-ក្រសួងមហាផ្ទៃ
-សាលាខេត្តកោះកុង
" <u>ដើម្បីជូនព្រាប</u> "
-ដូចប្រការ៣ ( <u>ដើម្បីអនុវត្តន៍</u>)
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រដ្ឋមន្ត្រី

ស៊ូរ-ឈន

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation - Religion - King

ទីស្តីការ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
Ministry of Posts and Telecommunications
លេខ : ១៧៨ បទ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១

# ប្រកាស

## ស្តីពីការចាត់តាំងប្រព័ន្ធវិទ្យុគមនាគមន៍
## សំរាប់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និង ទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/1198/72 ចុះថ្ងៃទី30ខែវិច្ឆិកា ឆ្នាំ1998 ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញព្រះរាជក្រមលេខ02នស94ចុះថ្ងៃទី 20.07.94ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

-បានឃើញព្រះរាជក្រម នសរកម0196-20ចុះថ្ងៃទី24.04.96ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

-បានឃើញអនុក្រឹត្យលេខ05 អនក្រចុះថ្ងៃទី05.03.87ស្តីពីប្រៃសណីយ៍ និងទូរគមនាគមន៍ ។

-បានឃើញអនុក្រឹត្យលេខ66អនក្របកចុះថ្ងៃទី22.10.97ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

-បានឃើញលិខិតលេខ06.317/01គជបចុះថ្ងៃទី24.05.2001របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## សំរេច

**ប្រការ ១** -អនុញ្ញាតិជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចាត់តាំងបណ្តាញវិទ្យុគមនាគមន៍ មានឈ្មោះ NEC មានចរិតលក្ខណៈសំរាប់ប្រតិបត្តិការ ចល័តនិងអចល័តតាមការបែងចែករលកអាកាសវិទ្យុ ដូចមានតារាងជូនភ្ជាប់ជាមួយ ។

**ប្រការ ២** -សញ្ញាហៅតិ XULM....សំរាប់វិទ្យុប្រភេទ VHFចល័តនិងអចល័ត និងបន្ថែមដោយ "ឈ្មោះសំគាល់ "នៃស្ថានីយ៍នីមួយៗតាមស្មារតីចាត់តាំងនិងគ្រប់គ្រងផ្ទាល់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង XUA20 ដល់XUA50 សំរាប់វិទ្យុប្រភេទ HFអចល័ត ។

**ប្រការ ៣** -គ្រប់ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងបណ្ដាអង្គភាពក្រោមឱវាទក្រសួងព្រមជាមួយនិងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានភារៈកិច្ចអនុវត្ត និងសហការតាមបញ្ញត្តិនៃវិទ្យុគមនាគមន៍ ។

**ប្រការ ៤** -ប្រកាសនេះមានប្រសិទ្ធភាពរយៈពេលមួយឆ្នាំនិងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

សូ-ខុន

**កន្លែងទទួល :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារប្រទេស
- សាលាក្រុងភ្នំពេញ

"ដើម្បីជូនជ្រាបជាពត៌មាន"

- រាជកិច្ច
- គ្រប់នាយកដ្ឋាន មន្ទីរ ប.ទខេត្ត ក្រុង "ដើម្បីអនុវត្ត"
- ឯកសារ -កាលប្បវត្ត

Annex: 1/1
Decision N°...........MPTC/FMLD dated:.............

NEC NetCell RADICOM

General Election'201

RADIO CHANNEL SETTING FOR FIEX[AND MOBILE OPERATION

| A-STATION ASSIGNMENT | QUANTITY |
|---|---|
| _KENWOOD (TRC-80) | 31 sets |
| _DIPOLE Antenna or tuner | 31 |

| 1-CH N° | CH ASSIGNMENT | 1-CH N° | CH ASSIGNMEN | 1-CH N° | CH ASSIGNMENT |
|---|---|---|---|---|---|
| 01 | 3.344MHz | 10 | 4.582MHz | 19 | 7.404MHz |
| 02 | 3.350MHz | 11 | 4.588MHz | 20 | 7.428MHz |
| 03 | 3.356MHz | 12 | 4.600MHz | 21 | 7.434MHz |
| 04 | 3.674MHz | 13 | 5.787MHz | 22 | 7.440MHz |
| 05 | 3.680MHz | 14 | 5.853MHz | 23 | 7.446MHz |
| 06 | 3.710MHz | 15 | 5.859MHz | 24 | 7.530MHz |
| 07 | 3.734MHz | 16 | 5.865MHz | 25 | 7.548MHz |
| 08 | 3.866MHz | 17 | 5.871MHz | 26 | 7.728MHz |
| 09 | 3.872MHz | 18 | 6.982MHz | 27 | 7.758MHz |
| | | | | 28 | 7.764MHz |
| | | | | 29 | 7.806MHz |

| B-STATION ASSIEGNMENT | QUANTITY |
|---|---|
| 1-1 KENWOOD TM-261A | 1654SETS |
| C144/W VARY LOOP ANTENNA&DU | |
| 1-2 KENWOOD TH-22AT (WALKIE TALKIE) | 2203SETS |

| 1Ch N° | CH ASSIGNMENT | 1Ch N° | CH ASSIGNMENT | 1Ch N° | CH ASSIGNMENT |
|---|---|---|---|---|---|
| 01 | 144.125MHz | 10 | 144.525MHz | 18 | 145.325MHz |
| 02 | 144.175MHz | 11 | 144.575MHz | 19 | 145.375MHz |
| 03 | 144.225MHz | 12 | 144.625MHz | 20 | 145.425MHz |
| 04 | 144.275MHz | 13 | 144.675MHz | 21 | 145.475MHz |
| 05 | 144.325MHz | 14 | 145.125MHz | 22 | 145.525MHz |
| 06 | 144.375MHz | 15 | 145.175MHz | 23 | 145.575MHz |
| 07 | 144.425MHz | 16 | 145.225MHz | 24 | 145.625MHz |
| 08 | 144.475MHz | 17 | 145.275MHz | 25 | 145.675MHz |
| 09 | 145.775MHz | | | | |

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation - Religion - King

ទីស្តីការ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
Ministry of Posts and Telecommunications

រាជធានី. ភ្នំពេញ ថ្ងៃទី ១៩...ខែកក្កដា ឆ្នាំ ២០០១

លេខ :១៤១ បទ.ប្រក

# ប្រ ក ា ស

## ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់មជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និងបណ្ណស័ព្ទ

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-យោងតាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០១

-បានឃើញការងារចាំបាច់របស់ក្រសួង

## ស ម្រ ច

**ប្រការ ១ :** មជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និង បណ្ណស័ព្ទគឺជាអង្គភាព ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស ។

**ប្រការ ២ :** មជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និង ប័ណ្ណស័ព្ទ មានភារៈកិច្ច និងសិទ្ធអំណាចដូចតទៅ :

ក-<u>អំពីភារៈកិច្ច</u>

-ផ្តល់សេវាទូរស័ព្ទសាធារណៈដល់អតិថិជន

-ផ្តល់សេវា Prepaid Service ដល់អតិថិជន

-គ្រប់គ្រងប្រតិបត្តិថែទាំជួសជុលបណ្តាញនិងរាល់ឧបករណ៍បរិក្ខាទាំងពីរ ( Payphone & PIN Phone

-សរុបប្រៀបធៀបទិន្នន័យការលក់ប័ណ្ណស័ព្ទ និងក្រាហ្វិកប្រើប្រាស់

-រៀបចំផែនការលើកទិសដៅចំណូល និងចំណាយរយៈពេលវែង ខ្លីតាមមុខសញ្ញារបស់ខ្លួនដើម្បីបង្កើនប្រភពចំណូល និងអភិវឌ្ឍន៍បន្ថែមលើវិស័យនេះ ដោយសហការជាមួយអង្គភាពមានសមត្ថកិច្ច ។

-សរុប និងធ្វើរបាយការណ៍ជាប្រចាំស្តីពីស្ថានភាពបច្ចេកទេសអាជីវកម្មជូននាយកដ្ឋាន

ខ-<u>សិទ្ធអំណាចរបស់មជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និង ប័ណ្ណស័ព្ទ</u>

១-អនុវត្តន៍ការងារដែលបានការអនុញ្ញាតិពីនាយកដ្ឋាន

២-រួមសហការជាមួយការិយាល័យ និងមជ្ឈមណ្ឌលនានាក្នុងនាយកដ្ឋាន និងបណ្តាអង្គភាពមានសមត្ថកិច្ច

៣-ធ្វើសេវាកម្ម អាជីវកម្ម ទូរស័ព្ទសាធារណៈ និង ប័ណ្ណស័ព្ទ

៤-សហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាទំនាស់បាតុភាពនានាដែលកើតមានឡើង

៥-កសាងបែបបទប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ឬ តុលាការ នូវរាល់បញ្ហាដែលកើតមានឡើង

៦-សហការជាមួយកំលាំងមានសមត្ថកិច្ចក្នុងការចុះបង្ក្រាបលុបបំបាត់ចោលនៅអំពើខុសច្បាប់ដែលបំពានក្នុងវិស័យទូរស័ព្ទសាធារណៈ និង ប័ណ្ណស័ព្ទ

៧-លើកសំណើជ្រើសរើសប្រធានផ្នែក និងបុគ្គលិកមានស្នាដៃល្អជូននាយកដ្ឋាន ។

**ប្រការ ៣ :** មជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និងប័ណ្ណស័ព្ទដឹកនាំដោយប្រធានមជ្ឈមណ្ឌល ១រូបនិងអនុប្រធានមួយចំនួនជាជំនួយការដែលត្រូវតែងតាំងដោយប្រកាសរបស់ក្រសួង ។

<u>ផ្នែកនានាចំណុះមជ្ឈមណ្ឌលរួមមាន</u> :

១-<u>ផ្នែកអាជីវកម្ម និង ទីផ្សារ</u> :

ផ្នែកអាជីវកម្ម និង ទីផ្សារ មានភារៈកិច្ច ធ្វើសេវាកម្មប័ណ្ណស័ព្ទ ត្រួតពិនិត្យប័ណ្ណស័ព្ទ សរុបទិន្នន័យ និង ផ្សព្វផ្សាយ ទីផ្សារអោយអតិថិជននិងប្រជាពលរដ្ឋយល់ច្បាស់អំពីការប្រើប្រាស់ទូរស័ព្ទសាធារណៈ និង ប័ណ្ណស័ព្ទ ។ ផ្នែកនេះមានក្រុមការងារចំនួន ៣ ក្រោមឱវាទ :

-ក្រុមសេវាប័ណ្ណទូរស័ព្ទ

-ក្រុមចល័ត និង ត្រួតពិនិត្យប័ណ្ណស័ព្ទ

-ក្រុមសរុបទិន្នន័យ

២-ផ្នែក Prepaid Service :

ផ្នែក Prepaid Service មានភារៈកិច្ចផ្តល់សេវា Prepaid និងស្ថាបនាជួសជុលប្រព័ន្ធបរិធានទូរស័ព្ទ Prepaid

ផ្នែកនេះមានក្រុមការងារចំនួន ២ ក្រោមឱវាទ :

-ក្រុមប្រចាំការ

-ក្រុមស្ថាបនាជួសជុល

៣-ផ្នែកប្រព័ន្ធគ្រប់គ្រងដំណើរការទូរស័ព្ទសាធារណៈ ( OPMS Operation Payphone Management System ) :

ផ្នែកប្រព័ន្ធគ្រប់គ្រងដំណើរការទូរស័ព្ទសាធារណៈ ( OPMS Operation Payphone Management System ) មានភារៈកិច្ចផ្តល់សេវាទូរស័ព្ទសាធារណៈស្ថាបនាជួសជុលបរិធានទូរស័ព្ទសាធារណៈ ត្រួតពិនិត្យចរាចរសេវាទូរស័ព្ទប្រចាំថ្ងៃ ប្រចាំខែ និង សំរង់ទិន្នន័យរាល់ហេតុការណ៍ ដែលបណ្តាលអោយមានការរអាក់រអួលដោយបរិធានឬបច្ចេកទេស ។

ផ្នែកនេះមានក្រុមការងារចំនួន ២ ក្រោមឱវាទ :

-ក្រុមប្រចាំការ

-ក្រុមស្ថាបនា និងជួសជុល

៤-ផ្នែកថែទាំជួសជុលបណ្តាញកាប្លិ៍ និង បរិធានទូរស័ព្ទសាធារណៈ :

ផ្នែកថែទាំជួសជុលបណ្តាញកាប្លិ៍ និង បរិធានទូរស័ព្ទសាធារណៈ មានភារៈកិច្ចជួសជុលថែទាំបណ្តាញត្រួតពិនិត្យរាល់បាតុភាពដែលកើតមានលើខ្សែបណ្តាញក្នុងករណីជនល្មើសលួចផ្តក់ខ្សែនៅចន្លោះ MDS និងបរិធានទូរស័ព្ទ

ផ្នែកនេះមានក្រុមការងារចំនួន ២ ក្រោមឱវាទ :

-ក្រុមជួសជុលបណ្តាញកាប្លិ៍

-ក្រុមជួសជុលថែទាំបរិធានទូរស័ព្ទ

ផ្នែកនិមួយ ៗ ខាងលើ ដឹកនាំដោយប្រធានផ្នែក ១រូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

រចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និងប័ណ្ណស័ព្ទ ជាឧបសម្ព័ន្ធ នៃប្រកាសនេះ ។

ដើម្បីអោយមជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និងប័ណ្ណស័ព្ទដំណើរការល្អនោះគ្រប់ផ្នែកត្រូវសំរេចអោយប្រសើរនូវការងារដែលមជ្ឈមណ្ឌលប្រគល់អោយ និងត្រូវសាមគ្គីឯកភាពគ្នាលើរាល់សកម្មភាព ។

ប្រការ ៤ : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥** : ខុទ្ទកាល័យ , អធិការដ្ឋាន គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារ នៃប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

គាត ឈន់

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៥ " ដើម្បីអនុវត្តន៍ "
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**រចនាសម្ព័ន្ធមជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និងបណ្ណស័ព្ទ**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន**

លេខ ..434...ក ក ន អ/ ០៩

## ប្រកាស

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

***

## រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន
- បានឃើញ ព្រះរាជក្រមលេខ០៦/នស/៩៤ចុះថ្ងៃទី៣០ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ លិខិតឯកភាពលេខ១៩៣ មស.គត ចុះថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ ២០០១ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងតាមការចាំបាច់របស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

## សំរេច

**ប្រការ១** : - តែងតាំងលោកស្រី **ឡុង និមល** ជាអនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស

- តែងតាំងលោកស្រី **សាន សាលីម** ជាអនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស
- តែងតាំងលោកស្រី **ឆាយ ចាំរីនេត្ត** ជាអនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស
- តែងតាំងលោកស្រី **ហ៊ូ និរមិត្តា** ជាអនុប្រធាននាយកដ្ឋានសុខភាព
- តែងតាំងលោកស្រី **អ៊ុង គឹមស្រេង** ជាអនុប្រធាននាយកដ្ឋានសុខភាព

**ប្រការ២** : អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានទាំងពីរ នាយកខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល-បុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ អង្គភាពពាក់ព័ន្ធ លោកស្រីដែលមានរាយនាមក្នុងប្រការ១ មានភារកិច្ចរៀងៗខ្លួនអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ ០៧ ឆ្នាំ ២០០០

**រដ្ឋមន្ត្រី**

**អ៊ឹង កន្ថាផាវី**

<u>ចម្លងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ "ដើម្បីជ្រាបជាពត៌មាន"
- ដូចប្រការ២ "ដើម្បីអនុវត្ត"
- ឯកសារ "កាលប្បវត្តិ"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ៧០៥ ក ធ ស ករ

—***—

## សេចក្តីសំរេច

## ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ១៣អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងលិខិតរបស់លោកស្រី ឡេង គីមណារេន នាយិកានៃអង្គការ មេត្រីអន្តរជាតិ ស្តីពីការសុំលុបចោលអង្គការ "មេត្រីអន្តរជាតិ" លេខ ២០-០១សអកអ ចុះថ្ងៃទី០៤ ខែ កក្កដា ឆ្នាំ ២០០១

## សំរេច

**ប្រការ១:** ប្រកាសបិទចោលទាំងស្រុងចំពោះសេចក្តីសំរេច របស់ក្រសួងធម្មការ និង សាសនា លេខ ២៨ កធស.សរ ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០០១ ស្តីពីការអនុញ្ញាតឱ្យបើកស្នាក់ការអង្គការ "មេត្រីអន្តរជាតិ" ដើម្បីធ្វើសកម្មភាពរបស់ខ្លួន ដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ២១ មណ្ឌលទី២ សង្កាត់បឹងកង់ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**ប្រការ២:** ខុទ្ទកាល័យ-នាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋានធម្មការ "នាយកដ្ឋានពាហិរសាសនា" គ្រប់ស្ថាប័ន-អង្គភាពដែលមានភារៈកិច្ចពាក់ព័ន្ធត្រូវសហការណ៍អនុវត្តន៍សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៣:** សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ

ភ្នំពេញ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០០១

រដ្ឋមន្ត្រី

ជា_សាវឿន

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
  "ដើម្បីជោគជូនជ្រាប"
- រាជកិច្ច ( ដើម្បីផ្សព្វផ្សាយ)

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ៧៧៦ ក ធ ស ក

—***—

## សេចក្ដីសំរេច

## ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១៩៦ ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ១៣អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅ របស់ក្រសួងធម្មការ និងសាសនា
- យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃក្រុមប្រឹក្សា "**បាប់ទីស្ទកម្ពុជា**" នៅខេត្តតាកែវ របស់លោកគ្រូ ម៉ុ ឈឹម អាយុ៣១ឆ្នាំ ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ១៩៩៩
- យោងចំណារបញ្ជូន របស់សាលាខេត្តតាកែវ លេខ ៣៧២សបង ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០០

## ស ម្រេ ច

**ប្រការ១:** អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ "**គ្រីស្ទបរិស័ទបាប់ទីស្ទត្រពាំងកោះ**" មួយកន្លែងដែលមានទីតាំងស្ថិតនៅ ភូមិត្រពាំងកោះ ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ ។

**ប្រការ២:** សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត "**គ្រីស្ទបរិស័ទបាប់ទីស្ទត្រពាំងកោះ**" ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ៣:** បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត "**គ្រីស្ទបរិស័ទបាប់ទីស្ទត្រពាំងកោះ**" ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ ដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្ដាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ៤:** រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយពីសេចក្ដីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥:** ខុទ្ទកាល័យ-នាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋានធម្មការ "**នាយកដ្ឋានពាហិរសាសនា**" គ្រប់ស្ថាប័ន-អង្គភាព ដែលមានការៈកិច្ចពាក់ព័ន្ធត្រូវសហការណ៍អនុវត្តន៍សេចក្ដីសំរេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៦:** សេចក្ដីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី១៥ ខែ ឧសភា ឆ្នាំ ២០០១

រដ្ឋមន្ត្រី

ជា_សាវឿន

**ចម្លងជូន**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- "ដើម្បីគោរពជូនជ្រាប"
- រាជកិច្ច ( ដើម្បីចុះផ្សាយ)
- សាលាខេត្តតាកែវ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ៧០៧ ក ធ ស ហ

— * * * —

## សេចក្តីសំរេច
## ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខនស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ១៣អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ របស់ក្រសួងធម្មការ និងសាសនា
- យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃក្រុមប្រឹក្សា " [illegible] " នៅខេត្តស្វាយរៀង របស់លោក ឆេង សុភ អាយុ៥៨ឆ្នាំ ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ១៩៩៨
- យោងលិខិតបញ្ជូន របស់សាលាខេត្តស្វាយរៀង លេខ ៣៥សកិ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

## សំរេច

**ប្រការ១:** អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " **ក្រុមជំនុំភូមិក្រពៀង** " មួយកន្លែងដែលមានទីតាំងស្ថិតនៅ ភូមិក្រពៀង ឃុំមុខដា ស្រុករមាសហែក ខេត្តស្វាយរៀង ។

**ប្រការ២:** សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " **ក្រុមជំនុំភូមិក្រពៀង** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ៣:** បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **ក្រុមជំនុំភូមិក្រពៀង** " ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ៤:** រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥:** ខុទ្ទកាល័យ-នាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានកិច្ចការសាសនា** " គ្រប់ស្ថាប័ន-អង្គភាព ដែលមានភារៈកិច្ចពាក់ព័ន្ធត្រូវសហការណ៍អនុវត្តន៍សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៦:** សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ ២០០១

រដ្ឋមន្ត្រី

ជា សាវឿន

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

" ដើម្បីគោរពជូនជ្រាប "

-រាជកិច្ច ( ដើម្បីចុះផ្សាយ)

-សាលាខេត្តស្វាយរៀង

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ៧០៨ ក ធ ស ភក

—***—

## សេចក្តីសំរេច

## ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស រកម/០១៩៦ ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ១៣អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ របស់ក្រសួងធម្មការ និងសាសនា
- យោងតាមពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃក្រុមប្រឹក្សា "ឈាមឪស្នេហ៍ខ្មែរ" នៅខេត្តកំពង់ធំរបស់លោក អ៊ុំ ឧះ អាយុ ៤៥ឆ្នាំ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៩
- យោងចំណារឯកភាព របស់សាលាខេត្តកំពង់ធំ លេខ ១៨៤បជ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០០

## សំរេច

**ប្រការ១:** អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ "**ផ្ការសាន**" មួយកន្លែងដែលមានទីតាំងស្ថិតនៅ ក្រុមទី១០ ភូមិប្រសោរ ឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ។

**ប្រការ២:** សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត "**ផ្ការសាន**" ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់ខ្លួនតាមគម្ពីរ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ៣:** បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត "**ផ្ការមាន**" ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ៤:** រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥:** ខុទ្ទកាល័យ-នាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋានធម្មការ "**នាយកដ្ឋានពាហិរសាសនា**" គ្រប់ស្ថាប័ន-អង្គភាព ដែលមានភារៈកិច្ចពាក់ព័ន្ធត្រូវសហការណ៍អនុវត្តន៍សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៦:** សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ១៩ ខែ ៤ ឆ្នាំ ២០០១

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

"ដើម្បីគោរពជូនជ្រាប"

- រាជកិច្ច ( ដើម្បីចុះផ្សាយ)
- សាលាខេត្តកំពង់ធំ

**ជា_សាវឿន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ៧០៤ ......ក ធ ស ក

— * * * —

## សេចក្តីសម្រេច

## ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស រកម/០១៩៦ ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ១៣អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ-ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ របស់ក្រសួងធម្មការ និងសាសនា
- យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃក្រុមប្រឹក្សា " ធម៌ទឹកសុខុមៈ " នៅខេត្តស្វាយរៀង របស់លោក ទិន ប៉ែន អាយុ៤៥ឆ្នាំ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៩
- យោងលិខិតបញ្ជូន របស់សាលាខេត្តស្វាយរៀង លេខ ៧០សក ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

## សម្រេច

**ប្រការ១:** អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " **ក្រុមជំនុំភូមិត្រពាំងស្លាច់** " មួយកន្លែងដែលមានទីតាំងស្ថិតនៅ ភូមិត្រពាំងស្លាច់ ឃុំជ្រៃធំ ស្រុករមាសហែក ខេត្តស្វាយរៀង ។

**ប្រការ២:** សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " **ក្រុមជំនុំភូមិត្រពាំងស្លាច់** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ៣:** បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **ក្រុមជំនុំភូមិត្រពាំងស្លាច់** " ត្រូវគោរព និង អនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះត្រូវបង្កើនសាមគ្គីភាពនិងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពនៃជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ៤:** រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយពីសេចក្តីសម្រេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥:** ខុទ្ទកាល័យ-នាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពាហិរសាសនា** " គ្រប់ស្ថាប័ន-អង្គភាព ដែលមានភារៈកិច្ចពាក់ព័ន្ធត្រូវសហការគ្នាអនុវត្តន៍សេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៦:** សេចក្តីសម្រេចនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

" **ដើម្បីគោរពជូនជ្រាប** "

- រាជកិច្ច ( ដើម្បីចុះផ្សាយ)
- សាលាខេត្តស្វាយរៀង

ភ្នំពេញថ្ងៃទី ១៩ ខែ ... ឆ្នាំ ២០០១

**ជា_សារឿន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងធម្មការ និង សាសនា**

លេខ ...........ក ធ ស

—***—

## សេចក្តីសំរេច

## ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១៩៦ ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ១៣អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ របស់ក្រសួងធម្មការ និងសាសនា
- យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃ "**សមាព័ន្ធគ្រិស្តបរិស័ទឯករាជ្យនិស្សកម្ពុជា**" នៅខេត្តកណ្តាលរបស់ លោក គិច ថៃអរ អាយុ២៩ឆ្នាំ ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ ១៩៩៩
- យោងចំណារបញ្ជូន របស់សាលាខេត្តកណ្តាល លេខ ០០៩សណ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០

## សំរេច

**ប្រការ១:** អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ "**គ្រួមជំនុំគ្រិស្តបរិស័ទឯករាជ្យនិស្សស្វាយតានី**" មួយកន្លែងដែលមានទីតាំងស្ថិតនៅ ផ្ទះលេខ ៧៦ ផ្លូវលេខ ២១ ក្រុមទី៧ ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ។

**ប្រការ២:** សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត "**គ្រួមជំនុំគ្រិស្តបរិស័ទឯករាជ្យនិស្សស្វាយតានី**" ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ៣:** បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត "**គ្រួមជំនុំគ្រិស្តបរិស័ទឯករាជ្យនិស្សស្វាយតានី**" ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ជាផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាព និងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនានិងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ៤:** រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥:** ខុទ្ទកាល័យ-នាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋានធម្មការ "**នាយកដ្ឋានពាហិរសាសនា**" គ្រប់ស្ថាប័ន-អង្គភាព ដែលមានភារកិច្ចពាក់ព័ន្ធត្រូវសហការអនុវត្តន៍សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៦:** សេចក្តីសំរេចនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០១

រដ្ឋមន្ត្រី

ជា_សាវឿន

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

"ដើម្បីគោរពជូនជ្រាប"

- រាជកិច្ច (ដើម្បីចុះផ្សាយ)
- សាលាខេត្តកណ្តាល
- មន្ទីរធម្មការ និងសាសនា ខេត្តកណ្តាល

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ៧៤១១..........ក ធ ស ក

—***—

## សេចក្តីសម្រេច
## ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស រកម/០១៩៦ ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ១៣អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ របស់ក្រសួងធម្មការ និងសាសនា
- យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃក្រុមប្រឹក្សា " **ឆាប់ស្នេកន្តុជា** " នៅខេត្តកំពង់ចាមរបស់លោក ឆេង ឈឿន អាយុ៥៧ឆ្នាំ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៩
- យោងចំណារបញ្ជូន របស់សាលាខេត្តកំពង់ចាម លេខ ២៩៩៤កច ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ១៩៩៩

## សំរេច

**ប្រការ១:** អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " **ក្រុមជំនុំគ្រីស្ទបរិស័ទឆាប់នីស្នេហ៍ធាតុ** " មួយកន្លែងដែលមានទីតាំងស្ថិតនៅផ្លូវលេខ ៦ ឃុំស្រម៉រ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។

**ប្រការ២:** សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " **ក្រុមជំនុំគ្រីស្ទបរិស័ទឆាប់នីស្នេហ៍ធាតុ** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ ទីផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ៣:** បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **ក្រុមជំនុំគ្រីស្ទបរិស័ទឆាប់នីស្នេហ៍ធាតុ** " ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពនៃជំនឿសាសនានិងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ៤:** រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥:** ខុទ្ទកាល័យ-នាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពហុសាសនា** " គ្រប់ស្ថាប័ន-អង្គភាព ដែលមានភារៈកិច្ចពាក់ព័ន្ធត្រូវសហការណ៍អនុវត្តន៍សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៦:** សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

" ដើម្បីគោរពជូនជ្រាប "

- រាជកិច្ច ( ដើម្បីចុះផ្សាយ )
- សាលាខេត្តកំពង់ចាម

ភ្នំពេញ ថ្ងៃទី ៧០ ខែ ឧសភា ឆ្នាំ ២០០១

រដ្ឋមន្ត្រី

ជា_សាវឿន

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ...........ក ធ ស ក

— * * * —

## សេចក្តីសំរេច

## ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រក/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ១៣អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ របស់ក្រសួងធម្មការ និងសាសនា
- យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃក្រុមប្រឹក្សា "ឯបង់ទីស្ទកម្ពុជា" នៅរាជធានីភ្នំពេញរបស់លោក ទ្រី ខណ្ណ អាយុ..ឆ្នាំ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ១៩៩៩
- យោងលិខិតបញ្ជាក់ព្រមព្រៀងពីទីតាំង របស់សាលាក្រុងភ្នំពេញ លេខ ៣៩៧៦ឆក.ស ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៩

## សំរេច

**ប្រការ១:** អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ "**គ្រិស្តបរិស័ទបាប់ទីស្ទភ្លើងឆេះរនេះ**" មួយកន្លែងដែលមានទីតាំងស្ថិតនៅក្រុមទី៣ ភូមិភ្លើងឆេះរទេះ ឃុំភ្លើងឆេះរទេះ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ។

**ប្រការ២:** សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត "**គ្រិស្តបរិស័ទបាប់ទីស្ទភ្លើងឆេះរនេះ**" ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ៣:** បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត "**គ្រិស្តបរិស័ទបាប់ទីស្ទភ្លើងឆេះរនេះ**" ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាព និងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ៤:** រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥:** ខុទ្ទកាល័យ-នាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋានធម្មការ "**ខាយកដ្ឋានពាណិជ្ជសាសនា**" គ្រប់ស្ថាប័ន អង្គភាព ដែលមានភារៈកិច្ចពាក់ព័ន្ធត្រូវសហការណ៍អនុវត្តន៍សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៦:** សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- "ដើម្បីគោរពជូនជ្រាប"
- រាជកិច្ច ( ដើម្បីចុះផ្សាយ)
- សាលារាជធានីភ្នំពេញ

ភ្នំពេញ ថ្ងៃទី ..០ ខែ កក្កដា ឆ្នាំ ២០០១

ជា_សារឿន

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ_______

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ១១៧........ក ធ ស ក

—***—

## សេចក្តីសំរេច
## ក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១៩៦ ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ របស់ក្រសួងធម្មការ និងសាសនា
- យោងពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃក្រុមប្រឹក្សា "ច្រិសសម្ព័ន្ធគ្រិស្តបរិស័ទកម្ពុជា " នៅខេត្តសៀមរាបរបស់លោក រស់ សារ៉ាយ អាយុ៤៧ឆ្នាំ, ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៩៨
- យោងចំណារបញ្ជូន របស់សាលាខេត្តសៀមរាប លេខ ១៧៧៦ខសរ ចុះថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ១៩៩៩

## សំ រេ ច

**ប្រការ១:** អនុញ្ញាតឱ្យបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តឈ្មោះ " **ណនូអេ** " មួយកន្លែងដែលមានទីតាំងស្ថិតនៅផ្ទះលេខ ៧២៤ ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

**ប្រការ២:** សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត " **ណនូអេ** " ត្រូវអនុញ្ញាតឱ្យប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់សាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

**ប្រការ៣:** បរិស័ទនៃសាខាស្នាក់ការព្រះគ្រិស្ត " **ណនូអេ** " ត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា ។ អ្នកដឹកនាំសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាពនិងទំនាក់ទំនងឱ្យបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាដាច់ខាតមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

**ប្រការ៤:** រាល់ការអនុវត្តន៍ទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥:** ខុទ្ទកាល័យ-នាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋានធម្មការ " **នាយកដ្ឋានពាណិជ្ជសាសនា** " គ្រប់ស្ថាប័ន-អង្គភាព ដែលមានភារៈកិច្ចពាក់ព័ន្ធត្រូវសហការណ៍អនុវត្តន៍សេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៦:** សេចក្តីសំរេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី២០ ខែ មិថុនា ឆ្នាំ ២០០១

រដ្ឋមន្ត្រី

ជា_សារឿន

__ចម្លងជូន__

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

" __ដើម្បីគោរពជូនជ្រាប__ "

- រាជកិច្ច ( __ដើម្បីចុះផ្សាយ__ )
- សាលាខេត្តសៀមរាប